# កប្បកថា

សម្តែងអំពីកប្បចំរើននិងកប្បវិនាស

មានភ្លើងឆេះកប្បជាដើម

ព្រះបាឡាត់ឧត្តមលិខិត សុង-ស៊ីវ

**សិទ្ធត្ថោ**

ដកស្រង់ប្រែរៀបរៀង

ព-ស ២៥១០ គ-ស ១៩៦៧

ការផ្សាយរបស់បណ្ណាគារ ជីង-ប៉ា-ហួត លេខ ១៤០ វិថី

ព្រះបាទអង្គអេង

ភ្នំពេញ

២៥៦.
១៤ខ

# ស្នាដៃនេះ

កើតឡើងពីកិច្ចសហការគ្នា រវាង

**ពុទ្ធសាសនបណ្ឌិត្យ** និង **បណ្ណាល័យអេឡិចត្រូនិចខ្មែរ**

ក្នុងគោលបំណងយ៉ាងមុតមាំដើម្បីថែរក្សា ការពារ កុំឲ្យបាត់បង់តទៅទៀត

ព្រមទាំងផ្សព្វផ្សាយស្នាដៃ-ឯកសារទាំងនេះ

សម្រាប់សាធារណជនប្រើប្រាស់ដោយមិនគិតកម្រៃ។

សូមថ្លែងអំណរគុណដល់

**អង្គការរីស្សូ កូសី-កៃ  វិទ្យាស្ថានបើកទូលាយ**

**ករុណាខ្មែរ និង មូលនិធិខ្មែរសម្រាប់ការសិក្សា**

ដែលបានគាំទ្រគម្រោងការស្នាដៃនេះ សម្រាប់ទុកក្នុងបណ្ណាល័យអេឡិចត្រូនិច។

Buddhist Institute of Ministry of Cult and Religion and eLibrary of Cambodia have made a cooperative effort to digitalize books and manuscripts in order to preserve our Cambodian literary heritage. This will promote and provide easy, instant access, free of charge to the public and future generations to come.

A sincere thank you to our generous supporters: Rissho Kosei-Kai, Open Institute, Karuna Cambodia and Cambodian Education Excellence Foundation, who made this endeavor possible.

www.budinst.gov.kh      www.elibraryofcambodia.org

២៥៦.១៤១

# កប្បកថា

សំដែងអំពីកប្បចំរើននិងកប្បវិនាស

មានភ្លើងឆេះកប្បជាដើម

ព្រះបាឡាត់ឧត្តមលិខិត សុង-ស៊ីវ

សិទ្ធត្ថោ

ដកស្រង់ប្រែរៀបរៀង

LIBRARY BUDDHIST INSTITUTE
៤០១/៩៥

បោះពុម្ពលើកទី ៦

ព.ស. ២៥១០ គ.ស ១៩៦៧

ការផ្សាយរបស់បណ្ណាគារជីន-ផាំ-ហួត លេខ ១៤០ វិថីព្រះបាទអង្គអេង

ភ្នំពេញ

# បញ្ជីមាតិកាធម៌


| មាតិកានុក្រម | លេខទំព័រ |
| --- | --- |
| ខាយប្រវត្តិជីវិត - - - - - | ១ |
| អំពីពាក្យថាកប្ប - - - - - | ២ |
| ទ្វីប ៤ - - - - - - | ៨ |
| ទំហំឈើប្រចាំទ្វីប - - - - - | ៩ |
| ទំហំទ្វីប - - - - - - | ១០ |
| ពុទ្ធក្ខេត្ត៣យ៉ាង - - - - - | ១១ |
| គ្រោងគំនិត - - - - - - | ១៥ |
| ឧបមាអំពីកប្ប - - - - - | ១៧ |
| ការបែកកប្ប - - - - - - | ១៩ |
| កប្បវិនាសដោយភ្លើង - - - - | ២២ |
| កប្បវិនាសដោយទឹកនិងខ្យល់ - - - | ២៥-២៦ |
| កប្បចំរើន - - - - - - | ២៧ |
| សត្វបរិភោគដីមានរស - - - - | ៣០ |
| រឿងព្រះបាទទឡ្ហនេមិ - - - - | ៣៩ |
| ការកើតអកុសលកម្មបថក្នុងលោក - - | ៤៥ |
| ការកើតសត្ថន្តរកប្ប - - - - | ៥០ |
| ការកើតកុសលកម្មបថក្នុងលោក - - - | ៥២ |

# វតនប្រណាម

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

ខ្ញុំព្រះករុណាសូមនមស្ការ ចំពោះព្រះភគវន្តមុនី អរហន្ត សម្មាសម្ពុទ្ធព្រះអង្គនោះ ព្រមទាំងព្រះធម៌ និងព្រះអរិយសង្ឃដោយ គោរព ។

សាធុំ សាធុំ ហានុ វិហគា វិហគា មយា
វន្ទិតា វន្ទិតា ហាន ភាជនេ រតនត្តយេ ។

កិរិយាថ្វាយបង្គំឯណា ដែលខ្ញុំព្រះករុណា បានធ្វើឡើងប្រកប ដោយសេចក្តីគោរព ក្នុងប្រជុំបីនៃរតនៈ មានព្រះពុទ្ធជាដើម ដែលជា ភាជន៍ គួរតែបុគ្គលថ្វាយបង្គំបូជា ដោយទ្វារទាំងបីមានកាយទ្វារជាដើម កិរិយាថ្វាយបង្គំនោះឯង ជាអំពើដ៏វិសេស ព្រោះញ៉ាំងសម្បត្តិជា លោកិយនិងលោកុត្តរៈឲ្យសម្រេចបាន សូមញ៉ាំងសេចក្តីក្រវល់ក្រវាយ ដែលប្រព្រឹត្តទៅក្នុងកាយនិងចិត្តនៃខ្ញុំព្រះករុណាឲ្យវិនាសបាត់បង់ទៅ ។

ថ្ងៃទី ១០ មិថុនា ឆ្នាំ ១៩៥២

ព្រះបាឡាត់ឧត្តមលិខិត សុន - ស៊ីវ

សិទ្ធត្ថោ

# អាទ្យារម្ភបទ

ការរៀបរៀងសៀវភៅនេះ ខ្ញុំបានដកស្រង់សេចក្ដីក្នុងគម្ពីរផ្សេង ៗ មានគម្ពីរទ័យនិកាយនិងវិសុទ្ធិមគ្គជាដើម ដែលមាននិយាយអំពីកព្យ យកមកប្រែរៀបរៀងប្រកបឲ្យកើតជាសៀវភៅនេះឡើង សន្មតឲ្យឈ្មោះថា «កព្យកថា» ការសំដែងអំពីកព្យ ដើម្បីជាគ្រឿងប្រដាប់សតិបញ្ញារបស់ពុទ្ធមាមកជនទូទៅ និងជាគ្រឿងពិចារណាក្នុងបញ្ហាដីកែ របស់សត្តខិករ និងវត្ថុគ្រប់ប្រភេទ ឲ្យឃើញប្រច័ក្សថាមានខ្លឹមសារ ឬមិនមាន, ទៀង ឬ មិនទៀង ។

សៀវភៅនេះ ខ្ញុំបានរៀបរៀងតាំងពី ព.ស. ២៤៩១ កាលដែលនៅជាសិស្សសាលាបាលីជាន់ខ្ពស់នៅឡើយ ប៉ុន្តែមិនបានឡើងកាន់ពុម្ព, ដល់មក ព.ស. ២៤៩៨ លោក ជឹង-ប៉ៅ បានមកអារាធនាឲ្យរៀបរៀងរឿងនេះដើម្បីបោះពុម្ពផ្សាយ ខ្ញុំក៏ជូនសៀវភៅនេះ ចំពោះលោក ជឹង-ប៉ៅ តែម្ដង ដើម្បីឲ្យចាត់ការបោះពុម្ពផ្សាយតាមសេចក្ដីត្រូវការ ។

វត្តលង្កា ថ្ងៃទី ១០ មិថុនា ឆ្នាំ ១៩៥៦

ព្រះបាឡាត់ឧត្តមលិខិត សុន-ស៊ុ

សិទ្ធត្ថោ

# កប្បកថា -១-

## ឧបាយប្រចាំជីវិត

ដើម្បីបន្ធូរបន្ថយចិត្តកុំឲ្យលិចលង់ទៅក្នុងអំពើទុច្ចរិតផ្សេងៗ គួរគិតពិចារណាដល់គ្រោះថ្នាក់ ការវិនាសអន្តរាយរបស់ពិភពលោក ដែលទុកជាផ្ទះសំបែងជាគូហាឬជាអទូន៍របស់យើង ដែលយើងត្រូវតែកើត ត្រូវតែនៅអាស្រ័យ គេចរត់ចៀសចេញមិនរួច ។ ធម្មតាអ្នកនៅក្នុងផ្ទះដែលចាក់សោជាប់ជាមួយ ហើយប្រហែសធ្វេសមិនគិតគូរដល់គ្រោះថ្នាក់គិតតែដេកសប្បាយក្នុងផ្ទះ បណ្ដោយសតិស្មារតីឲ្យវង្វេងភ្លេចបាត់ខ្លួនសោ ដល់វេលាភ្លើងឆេះផ្ទះ ស្រាប់តែភ័យញ័រញាប់ស្លុតព្រលឹងរត់ស្រែកអន្ទះសាទទួលទុក្ខសោកយ៉ាងខ្លាំង ដរាបដល់ភ្លើងឆេះខ្ទេចខ្ទីប្រកាច់ស្លាប់ក្នុងគំនរភ្លើងនោះ ។ មានឧបមាយ៉ាងណាមិញ អ្នកសត្វនិករក្នុងលោកដែលដេកនឹកស្ទុះស្ទួនគំនិតទៅក្នុងអំពើទុច្ចរិតផ្សេងៗ មិនបាននឹកដល់គ្រោះថ្នាក់ប្រចាំជីវិត គិតតែសប្បាយហួសហេតុ ខុសលំនាំអ្នកប្រាជ្ញក៏ដូច្នោះដែរ ។

ធម្មតាអ្នកប្រាជ្ញអ្នកមានគំនិតប្រព្រឹត្តទៅមុនជីវិត តែងរិះរកឧបាយដើម្បីចៀសវាងគ្រោះថ្នាក់ប្រចាំជីវិតទុកមុនជាដរាប មិនបណ្ដោយឲ្យជីវិតលឿនទៅប៉ះទង្គិចកានការលើគំនរគ្រោះថ្នាក់ឡើយ ។ ឧបាយ

ដែលនឹងចៀសវាងគ្រោះថ្នាក់នោះមានតែមួយទេ គឺសុចរិតធម៌, សុចរិតកាយ គឺមិនបៀតបៀនជីវិតរបស់ខ្លួននិងសត្វដទៃ មិនលួចប្លន់បុត្រភរិយាស្វាមីនិងទ្រព្យសម្បត្តិរបស់ជនដទៃនិងមិនផឹកសុរាជាដើម សុចរិតវាចា គឺមិននិយាយកុហកញុះញង់ បំបែកបំបាក់ពាក់ចុចធ្វើឲ្យអ្នកដទៃវិនាសជាដើម, សុចរិតចិត្ត គឺមិនគុំគួនព្យាបាទអ្នកដទៃ និងមិនជឿនិងធ្វើរូបបរបេសជំទាស់នឹងសភាពពិត ចេះជឿកម្មនិងផលរបស់កម្មជាដើម ។ បើបុគ្គលណាមានសុចរិតធម៌នេះហើយ បុគ្គលនោះជាបណ្ឌិតមានគំនិតល្អ មិនបណ្តោយឲ្យជីវិតលឿនទៅប៉ះទង្គិចពានពារលើគំនរគ្រោះថ្នាក់ឡើយ ។

ឯគ្រោះថ្នាក់នោះដោយសង្ខេបមាន ២ យ៉ាងគឺ:

១ - គ្រោះថ្នាក់មិនប្រចាំកាល

២ - គ្រោះថ្នាក់ប្រចាំកាល ។

១) គ្រោះថ្នាក់មិនប្រចាំកាលនោះ បានដល់គ្រោះថ្នាក់របស់សត្វជួបជាក្នុងបច្ចុប្បន្នកាលនេះ ។ ក្នុងប្រទេសមួយតំបន់មួយជាមួយគ្នា សត្វខ្លះមានគ្រោះថ្នាក់ ខ្លះបានសុខចំរើន ជួនកាលថ្ងៃខែឆ្នាំនេះ សត្វនោះមានគ្រោះថ្នាក់, ថ្ងៃខែឆ្នាំនោះ សត្វនេះមានគ្រោះថ្នាក់មិនកំណត់កាលកំណត់សត្វ ដូច្នេះហៅជាគ្រោះថ្នាក់មិនប្រចាំកាល ។

២ ) គ្រោះថ្នាក់ប្រចាំកាលនោះ បានដល់គ្រោះថ្នាក់ប្រចាំអាយុផែនដីយូរអង្វែងណាស់ទើបមានម្ដង ។ គ្រោះថ្នាក់នេះធំក្រៃលែងធំដែលពាក្យចាស់ទុំតែងនិយាយថា កើតអន្តរធានភ្លើងឆេះទឹកឆេះដី ភ្លើងប្រល័យកប្ប ។ ក្នុងពេលភ្លើងប្រល័យកប្បនោះពួកសត្វនិករដែលនៅលើផែនដីទាំងប៉ុន្មាន ទាំងនៅក្នុងស្ថានសួគ៌ទៅទល់ត្រឹមសុទ្ធាវាសព្រហ្មត្រូវទទួលគ្រោះថ្នាក់ទាំងអស់ចំពោះសត្វណាដែលធ្វេសប្រហែស មិនអើពើនឹងសុចរិតធម៌ ព្រោះក្នុងពេលនោះ ធម្មតាកុសលាកុសលកម្ម នឹងសង្គ្រាត្រូវបែងចែកសត្វ គឺសត្វណាដែលលោកប្រព្រឹត្តអំពើទុច្ចរិត សត្វនោះត្រូវទៅជួបជុំកើតក្នុងពេលនោះទីនោះ សត្វណាដែលបានប្រព្រឹត្តសុចរិតធម៌ហ្មត់ចត់ល្អសព្វនោះត្រូវទៅកើតនៅក្នុងឋានសុខក្សេមក្សាន្ត មានទៅកើតក្នុងសុទ្ធាវាសព្រហ្មជាដើម មិនបាននៅប្រឡូកប្រឡំជាមួយនឹងពួកអ្នកប្រព្រឹត្តទុច្ចរិតនោះឡើយ, ដូច្នេះហៅថាគ្រោះថ្នាក់ប្រចាំកាល ។ គ្រោះថ្នាក់នេះកាន់តែលឿនជិតមកដល់ហើយ ព្រោះផែនដីដែលយើងនៅអាស្រ័យសព្វថ្ងៃនេះ មានឈ្មោះតាមអាយុហៅថាភទ្ទកប្ប មានព្រះពុទ្ធ ៥ ព្រះអង្គត្រូវឧប្បត្តិកើតឡើងក្នុងរយៈកាលអាយុផែនដីនេះ, ឥឡូវបរិនិព្វានផុត ៤ ព្រះអង្គទៅហើយ គឺព្រះពុទ្ធកកុសន្ធោ កោនាគមនោ, កស្សបោ, គោតមោ, នៅសល់តែព្រះអរិយមេត្តេយ្យ

មួយព្រះអង្គទៀតទេ ត្រូវភ្លើងប្រល័យកប្បហើយ ។

ពាក្យថាកប្ប និងរឿងភ្លើងប្រល័យកប្បនោះ និងមានសំដែងតទៅនេះ ។

## អំពីពាក្យថាកប្ប

កាលដែលតាំងនៅហូរអន្លង់ហៅថាកប្ប ជាឈ្មោះអាយុផែនដី ឬជាឈ្មោះអាយុឧកាសលោក ។ ដែលហៅថាឧកាសលោកនោះ គឺគម្ពីរវិសុទ្ធិមគ្គប្រាប់ថា: បានដល់ទីកំនៅរបស់សត្តនិករ ដែលមានសេចក្ដីនាសជាធម្មតា ។ ក្នុងឧកាសលោកនោះ មានចក្កវាឡ (១) ជាច្រើន ចក្កវាឡមួយៗនេះមានបណ្ដោយទទឹងទីនប្រវែងមួយលានពីរសែនបីពាន់បួនរយហាសិបយោជន៍ (២) (១.២០៣.៤៥០ យោជន៍) បរិមណ្ឌលសំណុំមូលជុំវិញ បីលានប្រាំបួនសែនមួយម៉ឺនបីរយហាសិបយោជន៍ (៣៩១០.៣៥០ យោជន៍), កម្រាស់ផែនដីក្នុងចក្រវាឡនេះ ចំនួនពីរសែនបួនម៉ឺនយោជន៍ (២៤០ ០០០ យោជន៍) ទឹកទ្រផែនដីកម្រាស់បួនសែនប្រាំបីម៉ឺនយោជន៍ (៤៨០.០០០ យោជន៍) មានភ្នំឈ្មោះសិនេរុ ពាក់ប្រុសលិចទៅក្នុងសមុទ្រ ជម្រៅប្រាំបីម៉ឺនបួនពាន់

---

– ពាក្យថាចក្កវាឡគឺលោកធាតុទីទ្រទ្រង់លោក បានជាហៅថាចក្កវាឡ ព្រោះមានភ្នំព័ទ្ធជុំវិញដូចជាកង់រទេះ ។ ២ – មួយយោជន៍ប្រវែង ៤ គាវុត: ១ គាវុត ប្រវែង ៨០ ឧសភ, ១ ឧសភ ប្រវែង ២៥ ព្យាម, គឺ ១ យោជន៍ប្រវែង ៨ ពាន់ព្យាម ។

យោជន៍ (៨៤.០០០យោជន៍), ខ្ពស់ឡើងលើប្រាំបីម៉ឺនបួនពាន់យោជន៍ដូចគ្នា. បន្ទាប់អំពីភ្នំសិនេរុនោះមកមានភ្នំសត្តបរិភណ្ឌ ៧ ជាន់ទៀតគឺ

១ - យុគន្ធរ មានកំពស់ ៤២.០០០ យោជន៍

២ - ឥសិន្ធរ មានកំពស់ ២១.០០០ យោជន៍

៣ - ករវិក មានកំពស់ ១០.៥០០ យោជន៍

៤ - សុទស្សនៈ មានកំពស់ ៥.២៥០ យោជន៍

៥ - នេមិន្ធរ មានកំពស់ ២.៦២៥ យោជន៍

៦ - វិនតកៈ មានកំពស់ ១.៣១២ យោជន៍កន្លះ

៧ - អស្សកណ្ណ មានកំពស់ ៦៥៦ យោជន៍ពាក់កណ្ដាលកន្លះ ។

ភ្នំទាំង ៧ នេះសុទ្ធតែជាភ្នំទិព្វវិចិត្រដោយគេនវរត្នផ្សេងៗ មានមាសជាដើម, មានបុស្សលិចចុះទៅក្រោមពាក់កណ្ដាលស្មើនឹងកំពស់ឡើងលើ ស្ថិតនៅព័ទ្ធជុំវិញភ្នំសិនេរុ ចម្ងាយពីភ្នំមួយទៅភ្នំមួយ ប្រវែងស្មើនឹងកំពស់ភ្នំនោះៗ ត្រង់ចន្លោះភ្នំទាំង ៧ នោះសុទ្ធតែសមុទ្រទឹកគ្មានសរសៃ ហៅថាសមុទ្រសីទន្តរ ។ ភ្នំទាំង ៧ នេះនៅក្នុងស្ថានចាតុមហារាជិកាជាទីលំនៅនៃស្ដេចចតុលោកបាលទាំង ៤ គឺៈ ព្រះបាទធតរដ្ឋៈ ១ វិរូបក្ខៈ ១ វិរុឡ្ហកៈ ១ កុវេរៈ ១, នឹងជាទីនៅជាទីទៅមកនៃទេវតានិងយក្សទាំងឡាយ មិនមែនជាវិស័យរបស់មនុស្សលោកទៅដល់ មើលឃើញតែកម្មាន

ប្រមាណត្រូវឡើយ មានតែព្រះពុទ្ធនិងព្រះអរហន្តទាំងឡាយទើបទៅដល់ មើលឃើញ ដឹងស្គាល់ដោយសព្វគ្រប់ផុន (១) ។ ភ្នំធំឈ្មោះសិនេរុ នោះមានភ្នំ ៣ ទល់ទ្រពីក្រោម ហៅថាភ្នំត្រីកូដ, ខាងលើកំពូលភ្នំ សិនេរុនោះ ជាភូមិភាគរបស់សក្កទេវរាជ ហៅថាស្ថានតាវតិង្ស ខាង លើតទៅទៀតគឺស្ថានយាមា, តុសិត, និម្មានរតី, បរនិម្មិតវសវត្តី ។ ស្ថានទាំងនេះជាទីនៅអាស្រ័យរបស់ពួកទេវតាទាំងអស់ មិនមែនជាទីនៅ អាស្រ័យរបស់មនុស្សឡើយ ។ ខាងលើតពីស្ថានទេវតាទៅទៀត ជា ភូមិភាគរបស់ពួកព្រហ្មមានរូបនិងព្រហ្មគ្មានរូប ។

ព្រហ្មមានរូប ១៦ ស្ថានគឺ

| | |
|---|---|
| ១ – បរិសជ្ជា | ៧ – បរិត្តសុភា |
| ២ – បុរោហិតា | ៨ – អប្បមាណសុភា |
| ៣ – មហាព្រហ្មា | ៩ – សុភកិណ្ហា |
| ៤ – បរិត្តាភា | ១០ – វេហប្ផលា |
| ៥ – អប្បមាណាភា | ១១ – អសញ្ញិសត្តា |
| ៦ – អាភស្សរា | ១២ – អវិហា |

---

១ – អ្នកវិទ្យាសាស្ត្រ ភូមិសាស្ត្រ សម័យនេះមិនអាចបំប៉ោងខួរក្បាល គិតឲ្យដឹង សព្វដូចព្រះអរហន្តបានឡើយ ។ ព្រោះគ្មានមធ្យោបាយទៅដល់ ។

១៣ - អតប្បា
១៤ - សុទស្សា
១៥ - សុទស្សី
១៦ - អកនិដ្ឋា ។

ព្រហ្មគ្មានរូបមាន ៤ ស្ថានគឺ:

១– អាកាសានញ្ចាយតនៈ

២– វិញ្ញាណញ្ចាយយតនៈ

៣– អកិញ្ចញ្ញាយតនៈ

៤– នេវសញ្ញានាសញ្ញាយតនៈ

ស្ថាននេវសញ្ញានាសញ្ញាយតនៈនេះ ជាស្ថានខាងលើបំផុតរបស់ភពរបស់អាកាសលោក ។ ចម្ងាយពីទីបំផុតភពមកស្ថានមនុស្សលោកនេះ ឆ្ងាយក្រៃលែងឆ្ងាយឥតកំណត់រាប់ថាប៉ុណ្ណះប៉ុណ្ណោះយោជន៍មិនបាន ។ ក្នុងគម្ពីរលោកទីបកៈ មានសំដែងប្រៀបធៀបថា:

សត្តកវគ្គ បក្ខាន កូដាគារសមាសិសា ធាតិកា តីហោ វស្សហិ ទិមាសេហិ ច អឌ្ឍហិ រត្តិនិវហិ ... ដូច្នេះជាដើម ។ សេចក្តីថា ទេវតាមានឫទ្ធិច្រើន ស្ថិតនៅក្នុងទីបំផុតភព ហើយទម្លាក់ដុំថ្មធំប៉ុនផ្ទះកំពូល ឲ្យធ្លាក់ចុះមកស្ថានមនុស្សលោក ធ្លាក់មកយូរអង្វែងណាស់ចំនួន ៣ ឆ្នាំ ២ ខែ ៨ ថ្ងៃ និង ១៤ នាទី ទើបដល់ស្ថានមនុស្ស ដុំថ្មនោះគ្រាន់តែសឹកដោយខ្យល់ជាបអស់នៅសល់ប៉ុនផ្លែក្រូចសើចប៉ុណ្ណោះ ។

បន្ទាប់អំពីនេះ និងសំដែងរៀបរាប់តាមគម្ពីរវិសុទ្ធិមគ្គជាដើមតទៅទៀត ។ តាមដំណាលថា ភ្នំសិនេរុស្ថិតនៅកណ្ដាលចក្កវាឡ , ភ្នំសត្តបរិភណ្ឌព័ទ្ធជុំវិញភ្នំសិនេរុ, ផ្នែកខាងក្រៅភ្នំសត្តបរិភណ្ឌនោះសុទ្ធតែទឹកទាំងអស់ មានទ្វីប ៤ ស្ថិតនៅក្នុងទិសទាំង ៤ ឆ្ងាយដាច់ស្រយាលពីភ្នំសត្តបរិភណ្ឌ ។

## ទ្វីបទាំង៤នោះគឺ

១- ជម្ពូទ្វីប ស្ថិតនៅទិសខាងត្បូងភ្នំសិនេរុ មានដើមព្រីងប្រចាំទ្វីប មនុស្សក្នុងទ្វីបនោះរកស៊ីចិញ្ចឹមជីវិតដោយកសិកម្មនិងពាណិជ្ជកម្មជាដើម , ស្ត្រីមានគភ៌ ៩ ខែ ឬ ១០ ខែទើបប្រសូតបុត្រធីតា ។

២- ឧត្តរកុរុទ្វីប, ស្ថិតនៅទិសខាងជើងភ្នំសិនេរុ មានដើមកល្បព្រឹក្សប្រចាំទ្វីប, មនុស្សក្នុងទ្វីបនោះមិនរវល់កង្វល់ដោយកសិកម្មពាណិជ្ជកម្មឡើយ ចង់បានអ្វីចង់បរិភោគចំណីអាហារបែបណា គ្រាន់តែដើរទៅដល់ដើមកល្បព្រឹក្សបានដូចប្រាថ្នា , ស្ត្រីមានគភ៌ ៧ ថ្ងៃប្រសូតបុត្រធីតា ប្រសូតបាន ៧ ថ្ងៃចេះដើរចេះរត់ ។

៣- អមរគោយានទ្វីប ស្ថិតនៅទិសខាងលិចភ្នំសិនេរុ មានដើមកទម្ពប្រចាំទ្វីប, មនុស្សក្នុងទ្វីបនោះមិនកង្វល់ដោយកសិកម្មពាណិជ្ជកម្មឡើយ ព្រោះមានដូងកែវឲ្យសម្រេចសេចក្ដីប្រាថ្នាបានគ្រប់យ៉ាង ។

៤ – បុព្វវិទេហទ្វីប ស្ថិតនៅខាងកើតភ្នំសិនេរុ មានដើមប្រេសប្រចាំទ្វីប. មនុស្សក្នុងទ្វីបនោះមិនពិបាកនឿយហត់ដោយកសិកម្ម ពាណិជ្ជកម្មឡើយ ព្រោះមានប្រាសាទ ៗ វិចិត្របនាដោយកែវ ៧ ប្រការកំពស់ ១៥ យោជន៍ ឲ្យសម្រេចសេចក្ដីត្រូវការរបស់មនុស្សបានគ្រប់យ៉ាង ។

បណ្ដាទ្វីបទាំង ៤ នោះព្រះពុទ្ធគ្រប់ព្រះអង្គមិនដែលឧប្បត្តិកើតក្នុងទ្វីបទាំងបីទេ ទ្រង់ឧប្បត្តិកើតតែក្នុងជម្ពូទ្វីបមួយប៉ុណ្ណោះ ព្រោះទ្វីបទាំងបីជាទ្វីបសំកប់សម្ភោគផលរបស់សុចរិតធម៌ មិនមែនជាទ្វីបសំកប់សាងសុចរិតធម៌ដូចជម្ពូទ្វីបឡើយ ។

ក្នុងជម្ពូទ្វីបមានភ្នំហេមពាន្ត កំពស់ប្រាំរយយោជន៍ (៥០០ យោជន៍) បណ្ដោយនិងទទឹងប្រវែងបីពាន់យោជន៍ ( ៣.០០០ យោជន៍) មានកំពូលប្រាំបីម៉ឺនបួនពាន់ (៨៤.០០០ កំពូល) ។

## ទំហំដើមឈើប្រចាំទ្វីបទាំង ៤ គឺ:

ជម្ពូព្រឹក្ស ដើមព្រីងក្នុងជម្ពូទ្វីប ១, កប្បព្រឹក្ស ដើមកប្បក្នុងឧត្តរកុរុទ្វីប ១, កទម្ពព្រឹក្សដើមក្ទម្ពក្នុងអមរគោយានទ្វីប ១, សិរីសព្រឹក្ស ដើមប្រេសក្នុងបុព្វវិទេហទ្វីប ១, បារិឆត្តព្រឹក្សដើមល្ហុងផ្ទុងក្នុងស្ថានតាវតឹង្ស ១, បាដលីព្រឹក្សដើមជ្រខៀវរបស់ពួកអសុរ ១ និងសិម្ពលិព្រឹក្ស

ដើមរការបស់ពួកគ្រុឌ ១; ឈើទាំងអស់នេះសុទ្ធតែជាស្តេចនៃរុក្ខជាតិ មានអាយុរៀងតាំងនៅអស់ ១ កប្ប មានទំហំនិងកំពស់ជាដើមដូចគ្នាទាំងអស់គឺៈ មានទំហំជុំវិញដើមចំនួនដប់ប្រាំយោជន៍ (១៥ យោជន៍), បណ្ដោយដើមនិងបណ្ដោយមែកដែលបែកទៅជុំវិញដើមម្ខាង ៗ មានហាសិបយោជន៍ (៥០ យោជន៍) រីកាយមែកពីម្ខាងទៅម្ខាង និងកំពស់មែកទៅខាងលើចំនួនមួយរយយោជន៍ (១០០ យោជន៍) ។

## ទំហំទ្វីបទាំង៤យ៉ាងគឺៈ

ជម្ពូទ្វីបនិងស្ថានតាវតឹង្ស, ស្ថានអសុរ, ស្ថាននរកអវិចី មាន ទំហំមួយម៉ឺនយោជន៍ដូចគ្នា (១០.០០០ យោជន៍), អមរគោយានទ្វីបនិងបុព្វវិទេហទ្វីប មានទំហំពីរពាន់យោជន៍ (២.០០០ យោជន៍), ឧត្តរកុរុទ្វីប មានទំហំប្រាំបីពាន់យោជន៍ (៨.០០០ យោជន៍) ។ ទ្វីបទាំង៤នេះទ្វីបនីមួយៗ មានទ្វីបតូចៗ ប្រាំរយ ៗ ជាបរិវាររួមនៅក្នុងចក្រវាឡមួយ ជុំវិញចក្រវាឡមានភ្នំធំព័ទ្ធជុំវិញ ភ្នំនោះចាក់ឫសទៅក្នុងមហាសមុទ្រជម្រៅប្រាំបីម៉ឺនពីរពាន់យោជន៍ (៨២.០០០ យោជន៍) ផុតខ្ពស់ឡើងលើមានកំពស់ប្រាំបីម៉ឺនពីរពាន់យោជន៍ដែរ ។

## បញ្ជាក់សេចក្តី

ពាក្យថាលោកធាតុ និងចក្រវាឡ ជាពាក្យតែមួយគ្រាន់តែផ្សេងគ្នា

ដោយសេចក្ដីប៉ុណ្ណោះទេ ។ ក្នុងលោកធាតុមួយ ឬចក្កវាឡមួយមាន ទ្វីបធំ ៤ ទ្វីបតូច ៥ រយ ៗ, មានភ្នំសិនេរុ ភ្នំសត្តបរិភណ្ឌ, ស្ថានសួគ៌ ៦ ជាន់, ស្ថានព្រហ្ម, ស្ថានមនុស្សនឹងស្ថាននរកជាដើម ហើយមាន ព្រះអាទិត្យ ព្រះចន្ទ ។ ព្រះអាទិត្យនោះមានទំហំ ៥០ យោជន៍, ព្រះចន្ទ ទំហំ ៤៩ យោជន៍ ជាវិមានប្រាសាទរបស់សុរិយទេវបុត្រនឹងចន្ទទេវបុត្រ សន្ធារលោកគាត់តែងឡើងសំរាប់បំភ្លឺលោក មានប្រក្រតីដើរប្រទក្សិណ ភ្នំសិនេរុជានិច្ច, ព្រះអាទិត្យក្នុងមួយយប់មួយថ្ងៃដើរបានមួយជុំភ្នំសិនេរុ, ព្រះចន្ទដើរមួយខែទើបបានមួយជុំភ្នំសិនេរុ ។ រូបរួមសម្ភារៈទាំងអស់ ដូចរៀបរាប់មកនេះហៅថា លោកធាតុមួយ ឬ ចក្កវាឡមួយ ។

លោកធាតុឬចក្កវាឡនោះមានច្រើនជាអនេកមិនមែនមានតែមួយទេ រួមលោកធាតុឬចក្កវាឡដែលមានទាំងប៉ុន្មាន ហៅថា ឧកាសលោក ។ ឧកាសលោកនោះបែងចែកទៅតាមខេត្ររបស់ព្រះពុទ្ធទៀតគឺ៖

## ពុទ្ធក្ខេត្តមាន ៣ យ៉ាង

១- ជាតិក្ខេត្ត មានលោកធាតុឬចក្កវាឡចំនួនមួយម៉ឺន (១.០០០០ លោកធាតុ) ក្នុងពេលដែលព្រះសម្ពុទ្ធចាប់បដិសន្ធិនិងប្រសូតជាដើម លោកធាតុឬចក្កវាឡ ទាំងមួយម៉ឺននោះកំរើករំពើកញាប់ញ័រទាំងអស់ចាក់ ជួបជាមេចាប់ញាក់ឬចាប់អង្រួន ដោយអំណាចបុណ្យរបស់ព្រះអង្គ ។

២ - អាណាខេត្តមានលោកធាតុ ឬ ចក្រវាឡ ចំនួនមួយសែនកោដិ (១០០.០០០ កោដិលោកធាតុ) ក្នុងពេលដែលព្រះសម្ពុទ្ធសំដែងនូវរតនបរិត្ត, ខន្ធបរិត្ត, ធជគ្គបរិត្ត, អាដានាដិយបរិត្ត និងមោរបរិត្ត លោកធាតុ ឬ ចក្រវាឡទាំងមួយសែនកោដិនោះ ក៏រំភើបញាប់ញ័រទាំងអស់ ហាក់ដូចជាគេចាប់ញាក់ ឬ ចាប់អង្រួន ដោយអំណាចរបស់ព្រះបរិត្តដែលព្រះអង្គសំដែង ។

៣ - វិសយក្ខេត្ត មានលោកធាតុឬចក្រវាឡជាអនន្តរាប់មិនបានប្រ-មាណមិនត្រូវ, អំណាចប្រាជ្ញាញាណរបស់ព្រះសម្ពុទ្ធជ្រៅឆ្ងាយទូលាយជាអនន្ត ដូចយ៉ាងក្នុងអាកាសលោកដែលរកទីបំផុតមិនឃើញ បានតាមពុទ្ធបំណង បើព្រះអង្គចង់ជ្រាបនូវហេតុជាអនន្តដែលប៉ុណ្ណា ទ្រង់ជ្រាបបានប៉ុណ្ណោះឥតមានទើសទាក់ ។

ពុទ្ធក្ខេត្តទាំងបីនោះ លើកលែងវិសយក្ខេត្តមួយចេញព្រោះជាធម្មការវិស័យប្រាជ្ញាញាណរបស់ព្រះពុទ្ធគ្រប់ព្រះអង្គ ៗ ចំណែកខាងជាតិក្ខេត្តនិងអាណាខេត្ត ដែលមានលោកធាតុឬចក្រវាឡមួយសែនកោដិនោះ ជាខេត្តរបស់ព្រះសម្ពុទ្ធមួយព្រះអង្គ ៗ ។ លោកធាតុឬចក្រវាឡទាំងមួយសែនកោដិនោះ សណ្ឋានលោកធាតុកើតនៅទៀងក្នុងពេលជាមួយគ្នា មានអាយុស្ថិតនៅប្រហែលគ្នា វិនាសទៅវិញក៏ដំណាលគ្នា ដូចមានសំ-

ដែលក្នុងគម្ពីរវិសុទ្ធិមគ្គ ត្រង់អភិញ្ញានិទ្ទេសថា: ។

ឯវមេតេសុ តីសុ ពុទ្ធក្ខេត្តេសុ ឯកំ អាណាខេត្តំ វិនស្សតិ ។ តស្មិំ បន វិនស្សន្តេ ជាតិក្ខេត្តម្បិ វិនដ្ឋមេវ ហោតិ ។ វិនស្សន្តញ្ច ឯកតោវ វិនស្សតិ ។ សណ្ឋហន្តម្បិ ឯកតោវ សណ្ឋហតិ ។ តស្សេវំ វិនាសោ ច សណ្ឋហនញ្ច វេទិតព្វំ ។

សេចក្តីថា: បណ្តាពុទ្ធក្ខេត្តទាំងបីនោះ អាណាខេត្តមួយត្រូវវិនាស កាលបើអាណាខេត្តវិនាសហើយ ចំណែកខាងជាតិក្ខេត្ត ក៏ត្រូវវិនាសដូចគ្នា ។ ជាតិក្ខេត្ត កាលវិនាស ក៏វិនាសក្នុងពេលជាមួយគ្នានឹងអាណាខេត្ត, កាលតាំងនៅក៏តាំងនៅក្នុងពេលជាមួយគ្នានឹងអាណាខេត្ត ការវិនាសក្តី តាំងនៅក្តី នៃជាតិក្ខេត្តនិងអាណាខេត្តនោះបណ្ឌិតត្រូវជ្រាបយ៉ាងនេះចុះ ។

ន័យត្រង់ពុទ្ធក្ខេត្តនេះ ប្រែងមាននិយាយផ្សេងៗ គ្នា ខ្លះយល់ថា ក្នុងទីកាសលោកទាំងមូល ដែលមានមេឃអាកាសធំទូលាយល្ហល្ហេវនេះ មានលោកធាតុឬចក្កវាឡត្រឹមតែមួយសែនកោដិប៉ុណ្ណោះ យូរៗ ទើបមានព្រះពុទ្ធត្រាស់មួយអង្គ មិនមានជានិច្ចកាលរាល់ថ្ងៃរាល់ខែឆ្នាំទេ ព្រោះមិនមានលោកធាតុឬចក្កវាឡដោយឡែក ក្រៅពីមួយសែនកោដិនេះទៀត ។

ខ្លះទៀតយល់ថា ក្នុងអាកាសលោកធាតុធំមូលដែលតាមមេឃអាកាស ធំទូលាយល្ហល្ហើនេះ មិនមែនមានលោកធាតុបចក្កវាឡត្រឹមតែមួយសែនកោដិប៉ុណ្ណោះទេ គឺមានមួយសែនកោដិ ៗ ជាអនន្តរាប់មិនអស់មានព្រះពុទ្ធត្រាស់រាល់ ៗ ថ្ងៃគ្មានចន្លោះ គឺបើលោកធាតុមួយសែនកោដិនេះព្រះពុទ្ធបរិនិព្វានទៅហើយ លោកធាតុមួយសែនកោដិនោះ មានព្រះពុទ្ធកំពុង-ត្រាស់ដឹង, លោកធាតុមួយសែនកោដិឯណោះ មានព្រះពុទ្ធកំពុងចុះចាប់បដិសន្ធិ, លោកធាតុមួយសែនកោដិឯណោះ មានព្រះពុទ្ធកំពុងចេញបព្វជ្ជាឬមានលោកធាតុមួយសែនកោដិ ៗ ជាច្រើន ដែលមានព្រះពុទ្ធកំពុងតែចុះចាប់បដិសន្ធិ, កំពុងតែប្រសូតិ, កំពុងតែបានត្រាស់ជាដើម ឬក៏មានលោកធាតុមួយសែនកោដិជាច្រើនកំពុងតែវិនាស, មានលោកធាតុមួយសែនកោដិជាច្រើន ដែលកំពុងតែចំរើន ។

ការយល់ទាំងពីរស្ថាននេះ អ្នករៀបរៀងមិនបានវិនិច្ឆ័យថា ខាងណាខុសខាងណាត្រូវទេ ព្រោះតែទាញហេតុផលមកបង្ហាញជាគ្រាន់គំនិតទុកជាបានការ ស្រេចលើពុទ្ធបរិស័ទដែលបានមើលសៀវភៅនេះវិនិច្ឆ័យចុះ បើឃើញថាខាងណាសមហេតុសមផលជាង ខាងនោះហើយត្រូវពិតប្រាកដ ។

# គ្រោងគំនិត

១ – ពុទ្ធក្ខេត្តមាន ៣ គឺ ជាតិក្ខេត្ត, អាណាក្ខេត្ត, វិសយក្ខេត្ត ។ ខេត្ត ជាភាសាបាលី ប្រែថា ស្រែ, ដំបន់, នាទី... គឺភាគផែនដីឬភាគផែនលោក ដែលគេសន្មតបែងចែកជាផ្សេងៗ មានទំហំដោយផ្ទៃសកា បញ្ញត្តិ ឬដោយលោកបញ្ញត្តិជាសង្កាត់ៗ ក៏ឲ្យប្រែប្រួលគ្នា ព្រោះមានច្រើន មិនមែនមានតែមួយ ។

២ – ពុទ្ធក្ខេត្តទី ១ គឺជាតិក្ខេត្ត មានកំណត់ត្រឹមតែមួយម៉ឺនលោកធាតុ, ព្រះពុទ្ធទ្រង់ចាប់បដិសន្ធិជាដើម ចំពោះលោកធាតុណាមួយ ក្នុងក្រុមមួយម៉ឺនលោកធាតុនោះ កំរើករំពើកញ្ជាប់ញ័របានតែមួយម៉ឺនលោកធាតុប៉ុណ្ណោះ មិនបានកំរើកញ្ជាប់ញ័រ ដល់លោកធាតុដទៃទៀយ ។ ពុទ្ធក្ខេត្តទី ២ គឺ អាណាក្ខេត្ត មានកំណត់ត្រឹមតែមួយសែនកោដិលោកធាតុ, ព្រះពុទ្ធទ្រង់សំដែងនូវរតនបរិត្តនិងខន្ធបរិត្តជាដើម ក្នុងលោកធាតុណាមួយ ក្នុងក្រុមមួយសែនកោដិលោកធាតុនោះ កំរើករំពើកញ្ជាប់ញ័របានតែមួយសែនកោដិលោកធាតុប៉ុណ្ណោះ មិនកំរើករំពើកញ្ជាប់ញ័រដល់លោកធាតុដទៃទៀយ ។ ហេតុដូចម្តេច បានជាពុទ្ធក្ខេត្តទី ២ គឺអាណាក្ខេត្ត មានកំណត់នាទីមួយសែនកោដិលោកធាតុដូច្នេះ? មានលោកធាតុលើសពីមួយសែនកោដិទៅទៀតឬ? ឬក៏គ្មានទេ? បើគ្មានហេតុអ្វីក៏ចាំ

មានកំណត់ មានខេត្ត មិនថាតាំងអស់តែប៉ុនទៅ? ព្រោះការណ៍ខេត្ត នេះនិយាយចំពោះលោកធាតុក្នុងបច្ចុប្បន្នកាល មិនមែននិយាយចំពោះ លោកធាតុ ដែលកន្លងផុតទៅហើយនោះទេ ។

៣- ទោសលោកមេឃអាកាសនោះធំទូលាយជាអនន្តល្ហល្ហេវែក ឥតមិនផុតជើងមេឃមិនឃើញ សូម្បីពុទ្ធញាណក៏រកមិនឃើញដែរ ។ បើ ធំទូលាយយ៉ាងនេះលោកធាតុមួយៗសែនកោដិជាអនន្តក៏មិនបញ្ជៀតមេឃ អាកាសឡើយ ចាំងបីនេះជាគ្រាន់គំនិត សូមវិនិច្ឆ័យតាមន័យនេះចុះ ។

ដែលរៀបរាប់មកនេះវែកយកអំពីពាក្យថាកប្ប ព្រោះពាក្យថាកប្ប នេះជាឈ្មោះអាយុរបស់ផែនដី របស់អាកាសលោក ឬជាឈ្មោះអាយុ របស់លោកធាតុឬចក្កវាឡ ។ លោកធាតុ ឬ ចក្កវាឡតាំងមួយសែន កោដិដែលជាខេត្តរបស់ព្រះពុទ្ធម្ចាស់ ៗ នោះ សន្ធារលោកកាត់តែង សាងឡើងក្នុងពេលជាមួយគ្នា វិនាសទៅវិញក្នុងពេលជាមួយគ្នា គិត តាំងពីកើតឡើងទៅទល់នឹងពេលដែលវិនាសទៅវិញនោះ ច្រើនឆ្នាំ ណាស់ទុកបីជាមួយកោដិឬ មួយអសង្ខេយ្យឆ្នាំដូច្នេះមិនអស់ព្រោះលោក ធាតុឬចក្កវាឡនោះមានអាយុវែងណាស់ទើបអ្នកប្រាជ្ញដើមខ្សែតាំងឲ្យ មានព្រះពុទ្ធជាដើមសន្មតហៅថាកប្ប គឺលោកធាតុ ឬ ចក្កវាឡនោះមាន អាយុវែងមួយកប្បទើបវិនាសទៅវិញ ។

ក្នុងគម្ពីរសំយុត្តនិកាយត្រង់គណកដ្ឋវគ្គ មានសេចក្តីដំណាលថា: សម័យមួយព្រះសម្ពុទ្ធទ្រង់គង់នៅទៀបក្រុងសាវត្ថី មានភិក្ខុមួយរូបចូលទៅគាល់ ហើយក្រាបទូលសួរថា : បពិត្រព្រះអង្គដ៏ចំរើនកប្បមានកាលវែងប៉ុន្មាន ?

## ព្រះមានព្រះភាគទ្រង់ត្រាស់ថា:

ទីឃោ ខោ កប្បោ សោ ន សុករោ សង្ខាតុំ
ឯត្តកានិ វស្សានិ ឥតិ វា ឯត្តកានិ វស្សសតានិ ឥតិ
វា ឯត្តកានិ វស្សសហស្សានិ ឥតិ វា ឯត្តកានិ
វស្សសតសហស្សានិ ឥតិ វា ។

ម្នាលភិក្ខុ កប្បមានកាលវែងណាស់ កប្បនោះមិនងាយនឹងរាប់ថា ប៉ុណ្ណេះឆ្នាំក្តី ប៉ុណ្ណោះរយឆ្នាំក្តី ប៉ុណ្ណេះពាន់ឆ្នាំក្តី ឬថាប៉ុណ្ណេះសែនឆ្នាំបានឡើយ ។

ភិក្ខុនោះទូលសួរទៀតថា: បពិត្រព្រះអង្គដ៏ចំរើន ចុះព្រះអង្គអាចធ្វើពាក្យឧបមាបានឬទេ? ។

ព្រះមានព្រះភាគទ្រង់ត្រាស់ថាអាចធ្វើបាន ទើបទ្រង់សំដែងឧបមាថា :

សេយ្យថាបិ ភិក្ខុ មហាសេលោ បព្វតោ យោជនំ

មាយាមេន យោជនំ វិត្ថារេន យោជនំ ឧព្វេធេន

អច្ឆិទ្ទោ អសុសិរោ ឯកឃនោ តតោ បុរិសោ

វស្សសតស្ស វស្សសតស្ស អច្ចយេន កាសិកេន

វត្ថេន សកឹ សកឹ បរិមជ្ជេយ្យ ខិប្បតរំ ខោ សោ

ភិក្ខុ មហាសេលោ បព្វតោ ឥមិនា ឧបក្កមេន បរិក្ខយំ

បរិយាទានំ គច្ឆេយ្យ ន ត្វេវ កប្បោ ឯវំ ទីឃោ ខោ

ភិក្ខុ កប្បោ ។

ម្នាលភិក្ខុ ឧបមាដូចជាភ្នំថ្មសុទ្ធដ៏ធំ មានបណ្ដោយមួយយោជន៍ ទទឹងមួយយោជន៍ កំពស់មួយយោជន៍ មិនធ្លុះមិនមានប្រហោង ជាភ្នំតាន់ កន្លងមួយរយឆ្នាំ ១ ទៅ មានបុរសយកសំពត់កាសិកៈមកបោស ភ្នំនោះម្ដង ១ ម្នាលភិក្ខុ ភ្នំថ្មសុទ្ធដ៏ធំនោះ គប្បីដល់នូវការអស់ទៅ ហើយ ទៅដោយសេចក្ដីព្យាយាមនោះឆាប់ជាង ឯកប្បមិនទាន់អស់នៅឡើយ ម្នាលភិក្ខុ កប្បមានកាលវែងយ៉ាងនេះឯង ។

ក្នុងកាលជាខាងក្រោយមកមានភិក្ខុមួយរូបចូលទៅគាល់ហើយក្រាបទូលសួរដូចមុនទៀត, ព្រះមានព្រះភាគទ្រង់ត្រាស់ថា:

សេយ្យថាបិ ភិក្ខុ អាយសំ នគរំ យោជនំ អាយាមេន

យោជនំ វិត្ថារេន យោជនំ ឧព្វេធេន បុណ្ណំ

សាសបានំ គុឡិកាពទ្ធំ តតោ បុរិសា វស្សសតស្ស
វស្សសតស្ស អច្ចយេន ឯកមេកំ សាសបំ ឧទ្ធរេយ្យ
ខិប្បតរំ ខោ សោ ភិក្ខុ មហាសាសបកាសិ ឥមិនា
ឧបក្កមេន បរិក្ខយំ បរិយាទានំ គច្ឆេយ្យ ន ត្វេ
កប្បោ ឯវំ ទីឃោ ខោ ភិក្ខុ កប្បោ ។

ម្នាលភិក្ខុ ឧបមាដូចនគរដែលព័ទ្ធដោយកំពែង មានបណ្ដោយមួយយោជន៍ ទទឹងមួយយោជន៍ កំពស់មួយយោជន៍ពេញដោយគ្រាប់ស្ពៃ ជានគរគេបង្ហាប់ដោយជុំជិតស្អិត កន្លងមួយឆ្នាំៗ ទៅ មានបុរសទៅរើសយកគ្រាប់ស្ពៃមួយគ្រាប់ៗ អំពីគំនរនោះ, ម្នាលភិក្ខុ គំនរគ្រាប់ស្ពៃធំនោះ គប្បីដល់នូវការអស់ទៅ រលីងទៅដោយសេចក្ដីព្យាយាមនេះឆាប់ជាង ឯកប្បមិនទាន់អស់នៅឡើយ, ម្នាលភិក្ខុកប្បមានកាលវែងយ៉ាងនេះឯង ។

កប្បនេះចែកចេញជាច្រើនយ៉ាងទៅទៀត ចែកជា ២ ក៏មាន ជា ៣ ក៏មាន ជា ៤ ក៏មាន ជា ៦ ក៏មាន ។

## កប្បចែកជា ២ គឺ:

១– សំវដ្ដកប្ប   កប្បវិនាស

២– វិវដ្ដកប្ប   កប្បចំរើន ។

## បែកជា ៣ គឺ:

១- តេជោសំវដ្ដៈ — កប្បវិនាសដោយភ្លើង

២- អាបោសំវដ្ដៈ — កប្បវិនាសដោយទឹក

៣- វាយោសំវដ្ដៈ — កប្បវិនាសដោយខ្យល់ ។

## បែកជា ៤ គឺ:

១- អាយុកប្ប — ខួបអាយុ គឺខួបអាយុក្ស័យមនុស្ស

២- អន្តរកប្ប — កំណត់អាយុក្ស័យចុះខ័យឡើង

គឺមនុស្សមានអាយុក្ស័យចុះដល់ ១០ ឆ្នាំស្លាប់ ហើយខ័យឡើងវិញដល់អាយុមួយអសំខេយ្យ, ការខ័យចុះទៅហើយខ័យឡើងមកវិញមួយលើក ៗ ហៅថាអន្តរកប្បមួយ ៗ ។

៣- អសំខេយ្យកប្ប កំណត់យកអន្តរកប្ប ៦៤ ដងហៅថាអសំខេយ្យកប្បមួយ ។

៤- មហាកប្ប កំណត់យកអសំខេយ្យកប្ប ៤ ដងទើបហៅថាមហាកប្បមួយ ។

## បែកជា ៤ ទៀតគឺ:

១- សំវដ្ដកប្ប គិតតាំងពីពេលដែលកប្បវិនាស ទៅទល់និង

វិនាសអស់រលីង ។

២- សំវដ្ដដ្ឋាយីកប្ប គិតតាំងពីពេលដែលកប្បវិនាសអស់រលីង ទៅទល់នឹងពេលដែលកើតឡើងទៀត ។

៣- វិវដ្ដកប្ប គិតតាំងពីពេលដែលកប្បកើតឡើងទៅទល់នឹងពេលដែលព្រះអាទិត្យព្រះចន្ទកើតមាន ។

៤- វិវដ្ដដ្ឋាយីកប្ប គិតតាំងពីពេលដែលព្រះអាទិត្យព្រះចន្ទកើតមានទៅទល់នឹងពេលដែលកប្បវិនាសទៅវិញ ។

## បែកជា ៦ គឺ:

១- សារកប្ប កប្បដែលមានព្រះពុទ្ធត្រាស់តែ ១ ព្រះអង្គ

២- មណ្ឌកប្ប កប្បដែលមានព្រះពុទ្ធត្រាស់ ២ ព្រះអង្គ

៣- វរកប្ប កប្បដែលមានព្រះពុទ្ធត្រាស់ ៣ ព្រះអង្គ

៤- សារមណ្ឌកប្ប កប្បដែលមានព្រះពុទ្ធត្រាស់ ៤ ព្រះអង្គ

៥- ភទ្ទកប្ប កប្បដែលមានព្រះពុទ្ធត្រាស់ ៥ ព្រះអង្គ

៦- សុញ្ញកប្ប កប្បដែលគ្មានព្រះពុទ្ធត្រាស់ ។

អធិប្បាយអំពីកប្បវិនាសនឹងកប្បចំរើន

# អំពីកប្បវិនាស

កប្បដែលវិនាសទៅវិញដោយហេតុ ៣ យ៉ាងគឺ:

១ វិនាសដោយភ្លើងឆេះ កាលបើលោកធាតុប្តូចក្កវាឡទាំង ១ សែនកោដិមានអាយុគ្រប់មួយកប្បហើយ, ត្រូវភ្លើងឆេះកំទេចលោកធាតុទាំងនោះ មុនដែលមិនភ្លើងឆេះនោះ មានភ្លៀងធំធ្លាក់ចុះក្នុងលោកធាតុទាំង ១ សែនកោដិ មនុស្សទាំងឡាយនាំគ្នាត្រេកអរសប្បាយព្រោះបណ្តុះពូជធញ្ញជាតិផ្សេង ៗ កាលបើដុះល្មមតែស៊ីបានហើយ ភ្លៀងក៏រាំងលែងធ្លាក់ចុះមកទៀតអស់សែនឆ្នាំជាច្រើន ។ សត្វដែលមានកម្មស្រាល ៗ ក៏ស្លាប់មុនសត្វដែលមានកម្មធ្ងន់ បានទៅកើតក្នុងព្រហ្មលោកទាំងអស់ ។ លុះកាលកន្លងយូរទៅទឹកដែលដក់នៅក្នុងរនោះ ៗ រីងអស់ទៅ ពួកសត្វទាំងឡាយមានត្រីនិងអណ្តើកជាដើមក៏ស្លាប់អស់ទៅ ។ សត្វនរកក្តី[1] តិរច្ឆានក្តីមនុស្សក្តីស្លាប់ទៅបានទៅកើតក្នុងទេវលោក ខំចំរើនឈានក្នុងរវាងនោះ បានទៅកើតក្នុងព្រហ្មលោកទាំងអស់ ។ ធ្វើមុនដែលភ្លើងឆេះចំនួនជាមួយសែនឆ្នាំមានទេវតាមួយអង្គឈ្មោះលោកព្យូហាចុះអំពីទេវលោកមក ក្លែងភេទជាមនុស្សស្លៀកសំពត់ក្រហមរំសាយសក់ មានមុខទទឹកដោយទឹកភ្នែក ជូតទឹកភ្នែកហើយដើរទៅតាមផ្លូវមនុស្សប្រកាស

---

១. សត្វនរកស្លាប់ក្នុងពេលដែលព្រះអាទិត្យទី ៥ កើតឡើង ។

ប្រាប់ថា អ្នកទាំងឡាយ នៅមួយសែនឆ្នាំទៀតកប្បនឹងវិនាស លោកនឹងវិនាស ទឹកសមុទ្រនឹងរីងខះ ផែនដីក្តីព្រះសុមេរុទេវលោកព្រហ្មលោកនឹងវិនាស, អ្នកទាំងឡាយចូរចំរើនមេត្តាភាវនានឹងទំបំរើមាតាបិតាដោយគោរព ។ ក្នុងពេលនោះមនុស្សទាំងឡាយជាសប្បុរសបានស្តាប់ពាក្យទេវតានោះហើយ ក៏កើតសំវេគតក់ស្លុតមុខគេ ប្រញាប់ប្រញាល់ធ្វើបុណ្យទានបំរើមាតាបិតាមិនមានសេចក្តីប្រមាទ លុះដល់ស្លាប់ទៅបានទៅកើតក្នុងទេវលោក ទំបំរើនឈានក្នុងទេវលោក បានសម្រេចឈានក៏បានទៅកើតក្នុងព្រហ្មលោកទៅ មិនបានទៅរងទុក្ខវេទនាយូរដូចជាជនអសប្បុរសឡើយ ។

- ក្នុងគម្ពីរវិសុទ្ធិមគ្គប្រាប់ថា:

វស្សូបច្ឆេទតោ បន ឧទ្ធំ ទីឃស្ស អទ្ធុនោ អច្ចយេន ទុតិយោ សុរិយោ បាតុភវតិ . . . ដូច្នេះជាដើម ។

សេចក្តីថា: រាប់តាំងអំពីកាលដែលរាំងភ្លៀង ក្នុងកាលមកជាយូរអង្វែង មានព្រះអាទិត្យទី ២ កើតឡើងប្រាកដ ។ កាលព្រះអាទិត្យពីរមានក្នុងលោកហើយយប់នឹងថ្ងៃមិនប្រាកដ ។ ព្រះអាទិត្យមួយរះឡើង មួយលិចទៅ, ក្នុងលោកមានកំដៅព្រះអាទិត្យជាប់ជានិច្ចកាលវេលា ។ ក្នុងកាលមុនអំពីកាលដែលព្រះអាទិត្យញ៉ាំងកប្បឲ្យ

វិនាសនោះ សុរិយទេវបុត្រតែងមានក្នុងសុរិយវិមាន ដល់មកក្នុងកាល ដែលព្រះអាទិត្យញាំងកប្បឲ្យវិនាសនោះសុរិយវិមាន មិនមានទេវបុត្រឡើយ ។ សុរិយមណ្ឌលដែលកើតឡើងមានកំដៅក្លាហានណាស់ពពកនិងអព្ភក្នុងអាកាសវិនាសបាត់អស់ ផ្ទៃអាកាសប្រាសចាកមន្ទិល ។ កាលបើព្រះអាទិត្យ ២ កើតមកក្នុងលោកហើយ ទឹកក្នុងស្ទឹងតូច ។ រីងខះអស់ឥតសល់ ។ លុះកន្លងកាលយូរទៅព្រះអាទិត្យទី ៣ កើតឡើង ទឹកក្នុងស្ទឹងធំទាំង ៥ ក៏រីងខះអស់ទៀត ។ លុះកាលកន្លងយូរទៅ ព្រះអាទិត្យទី៤ កើតឡើង ។ ទឹកក្នុងស្រះធំទាំង ៧ មានស្រះអនោតត្តជាដើមក៏រីងខះអស់ទៀត ។ លុះកាលកន្លងយូរទៅ ព្រះអាទិត្យទី ៥ កើតឡើង ទឹកក្នុងមហាសមុទ្រក៏រីងខះអស់ទៀត, ក្នុងលោកទាំងមូលគ្មានទឹកមួយដំណក់ឡើយ ។ លុះកន្លងកាលយូរទៅព្រះអាទិត្យទី ៦ កើតឡើង ចក្កវាឡទាំងមួយសែនកោដិមានផ្សែងហុយទ្រលោមឡើង មានជ័រហូរចេញអំពីផែនដី ។ លុះកន្លងយូរទៅព្រះអាទិត្យទី ៧ កើតឡើង ចក្កវាឡទាំងមួយសែនកោដិ មានអណ្តាតភ្លើងឆេះសន្ធោសន្ធៅ ឆេះរំលាយក្នុងកំពស់មួយយោជន៍ ។ ជាដើមដរាបដល់ក្នុងសិនេរុ បណ្ដាលឲ្យវិនាសសាបសូន្យទៅ ។ អណ្តាតភ្លើងដែលឆេះនោះក៏ឆេះស្ថានចាតុមហារាជិកា ឆេះស្ថានតាវតិង្ស, ស្ថានយាមា, ស្ថានតុសិត, ស្ថាននិម្មានរតី,

ស្ថានបរនិម្មិតវសវត្តី គឺដ៏នេះនូវស្ថានព្រហ្មជាន់ខាងក្រោមទៅទល់ត្រឹមស្ថានអាភស្សរៈ ។

សា យាវ អណុមត្តម្បិ សង្ខារគតំ អត្ថិ តាវ ន និព្វាយតិ ។

អណ្ដាតភ្លើងនោះ បើរបស់ដែលនេះនោះមិនទាន់អស់ ក៏មិនទាន់រលត់ ព្រោះដែរបដល់អស់មិនឲ្យសល់ផេះ ទើបរលត់ទៅ ឧបមាដូចជាភ្លើងនេះប្រេង ។ ទីខាងក្រោមជាអាកាសទទេ ខាងលើក៏ជាអាកាសទទេដូចគ្នាទាំងអស់មានងងឹតងំតែមួយ ។

៦ - វិនាសដោយទឹក កាលបើលោកធាតុ ចូលកប្បមានអាយុមួយកប្បហើយ ត្រូវវិនាសទៅវិញ ។ ការដែលវិនាសដោយទឹកនោះ មានចំនួនដូចគ្នានឹងវិនាសដោយភ្លើងដែរ គ្រាន់តែប្ដូរដូច្នេះគឺៈមហាមេឃបណ្ដាលភ្លៀងទឹកក្រុតធ្លាក់ចុះមកក្នុងចក្កវាឡទាំងមួយសែនកោដិ សម្ភារៈទាំងឡាយមានកំដៅដើម កាលបើត្រូវទឹកក្រុតហើយ ក៏រលាយរលួយអស់ទៅ ទឹកក្រុតនោះឡល់បក់ច្រូចដីជុំវិញ រំលាយនូវសម្ភារៈ ខាងក្រោមហើយ រំលាយនូវស្ថានសួគ៌ ៦ ជាន់ និងស្ថានព្រហ្មជាច្រើនជាន់ទៀតទៅទល់ត្រឹមស្ថានព្រហ្មឈ្មោះ សុភកិណ្ហា ។ ទឹកក្រុតក៏ស្រកអស់ទៅ, សម្ភារៈទាំងឡាយមានកំដៅដើម ដែលរលាយដោយទឹកក្រុតនោះ ឧបមាដូចជាអំបិលដែលបន់ទៅក្នុងទឹក រលាយអស់ឥតមានសល់អ្វីតិចតួច

ឡើយ ។ ទីខាងក្រោមជាអាកាសទទេ ខាងលើក៏ជាអាកាសទទេដូចគ្នាទាំងអស់ មានងងឹតជាំតែមួយ ។

៣ - កប្បវិនាសដោយខ្យល់ កាលបើលោកធាតុឬចក្កវាឡមានអាយុមួយកប្បហើយ ត្រូវវិនាសទៅវិញ ។ ការដែលវិនាសដោយខ្យល់នោះ មានទំនងដូចគ្នានឹងវិនាសដោយភ្លើងដែរ គ្រាន់តែផ្ទុយគ្នា ដូច្នេះគឺ មហាមេឃញាំងខ្យល់ព្យុះធំឲ្យកើតឡើងបក់បំប៉ើងធូលីល្អិត ឲ្យហុយទៅឰដ៏អាកាសវិនាសបាត់អស់ទៅជាមុន ទើបបក់បំប៉ើងនូវដីខ្សាច់ក្រួសតូចធំនិងដុំថ្មកប់ផល់ដើមឈើនិងភ្នំឲ្យប៉ះទង្គិចគ្នា អណ្តែតទៅឰដ៏អាកាស វិនាសអស់គ្មានសល់ក៏ទេ ទើបបក់បំបែកនូវផែនដីក្តីមួយសែនកោដិចក្កវាឡនិងស្ថានសួគ៌ ៦ ជាន់ ស្ថានព្រហ្ម រហូតទៅដល់ស្ថានព្រហ្មឈ្មោះវេហប្ផលា ឲ្យល្អិតល្អន់ខ្ទេចខ្ទីអស់គ្មានសល់ធូលីបន្តិចបន្តួចឡើយ ។ ខ្យល់ក៏វិនាសបាត់អស់ទៅ, ទីខាងក្រោមជាអាកាសទទេ ខាងលើក៏ជាអាកាសទទេដូចគ្នាទាំងអស់ មានងងឹតជាំតែមួយ ។

កប្បដែលវិនាសទៅវិញ ដោយអាការៈបីយ៉ាងដូចរៀបរាប់មកនេះឯង ។ អាការៈទាំងបីយ៉ាងនេះមិនមែនវិនាសផ្លាស់ប្តូរតាមគ្នា ។ ម្តងទេ គឺវិនាសយ៉ាងនេះ ៖

វិនាសដោយភ្លើង ៧ ដង ត្រូវវិនាសដោយទឹកម្ដង, វិនាសដោយភ្លើងនិងទឹក ៗ តែយ៉ាងនេះចំនួន ៦៣ ដង ទើបវិនាសដោយខ្យល់ម្ដង នេះជាលំនាំនៃការវិនាសរបស់កប្ប ។

គម្ពីរវិសុទ្ធិមគ្គប្រាប់អំពីហេតុដែលបណ្ដាលឱ្យវិនាសថា:

អកុសលមូលេសុ ហិ ឧស្សន្នេសុ ឯវំ លោកោ វិនស្សតិ ។ សោ ច ខោ រាគេ ឧស្សន្នតរេ អគ្គិនា វិនស្សតិ ទោសេ ឧស្សន្នតរេ ឧទកេន វិនស្សតិ ។ កេចិ បន ទោសេ ឧស្សន្នតរេ អគ្គិនា រាគេ ឧស្សន្នតរេ ឧទកេនាតិ វទន្តិ មោហេ ឧស្សន្នតរេ វាតេន វិនស្សតិ ។

១ សេចក្ដីថា: កាលបើអកុសលមូលទាំងឡាយគឺ: រាគៈ ទោសៈ មោហៈ ក្រាស់ឡើងហើយ លោកតែងវិនាសដោយអាការៈយ៉ាងនេះ ។ លោកនោះឯង កាលបើមានរាគៈក្រាស់ជាង ត្រូវវិនាសដោយភ្លើង, បើមានទោសៈក្រាស់ជាង ត្រូវវិនាសដោយទឹក ។ ចំណែកខាងកេចិអាចារ្យនិយាយថា: កាលបើមានទោសៈក្រាស់ជាង ត្រូវវិនាសដោយភ្លើង, បើមានរាគៈក្រាស់ជាងត្រូវវិនាសដោយទឹក ។ បើមានមោហៈក្រាស់ជាង ត្រូវវិនាសដោយខ្យល់ ។

ចប់កប្បវិនាសដោយសង្ខេប

# កប្បចំរើន

ធម្មតាសង្ខារលោក កាលបើកប្បមុនវិនាសអស់ហើយ សង្ខារលោកត្រូវសាងលោកជាថ្មីឡើងទៀត ។ ការសាងលោកជាថ្មីនោះ មុមដំបូងមហាមេឃបង្អុរនូវទឹកភ្លៀង ឲ្យធ្លាក់ចុះមកបំពេញចក្កវាឡទាំងមួយសែនកោដិ មុនដំបូងមានដំណក់ភ្លៀងតូច ៗ ដូចជាទឹកសន្សើមយូរ ៗ ទៅ គ្រាប់ភ្លៀងកាន់តែធំឡើង ៗ ប៉ុនដើមល្ពក, ប៉ុនឈើសូល, ប៉ុនអង្រែ, ប៉ុនដើមត្នោត ដរាបដល់មានគ្រាប់ប៉ុន ១ ភ្នំ ។ ខ្យល់ក៏បក់ទឹកនោះឲ្យឃនខាប់, ទឹកនោះមានសណ្ឋានដូចជាទឹកដក់នៅលើស្លឹកឈូក ទើបហួតខះស្រកចុះទៅវិញជាលំដាប់ ។ ករៈដែលភ្លៀងនោះយូរណាស់ មិនចេះរាំងម្ដងឡើយ ចំនួនជាមួយកប្បទើបរាំង គឺនរទឹកខះទៅទល់ត្រឹមស្ថានព្រហ្ម ។ កាលបើខ្យល់ហួតទឹកនោះឲ្យរីងខះស្រកចុះហើយ ស្រកដល់កន្លែងដែលជាស្ថានព្រហ្មពីពេលមុន ក៏កើតជាស្ថានព្រហ្មទៅ ស្រកដល់កន្លែងស្ថានសួគ៌ ៦ ជាន់ ក៏កើតជាស្ថានសួគ៌ទៅ, ស្រកដល់កន្លែងកើតភ្នំ កើតទ្វីប កើតកោះ កើតសមុទ្រ ក៏កើតជាភ្នំ ជាទ្វីប ជាកោះជាសមុទ្រទៅ ។ សង្ខារលោកតាក់តែងក្នុងពេលមុនមានសភាពបែបណា សង្ខារលោកតាក់តែងក្រោយ ក៏មានសភាពបែបនោះ ឥតមានខុសគ្នាឡើយ ។

កាលបើទឹកស្រកចុះមកដល់ទីនឹងកើតភូមិហើយ ពពុះទឹកនោះមានរសផ្អែមកកកើតជាដី ដីដែលកើតឡើងនោះអណ្តែតលើទឹកដូចជាស្លឹកឈូកអណ្តែតលើទឹកឬដូចជាទឹកដោះក្តៅលាយអណ្តែតលើទឹក ។ ផែនដីមានរសនោះ មានសម្បុរល្អ មានក្លិនក្រអូប មានរសផ្អែម មានសម្បុរដូចជាទឹកដោះថ្លា មានរសឆ្ងាញ់ពីសាដូចជាទឹកឃ្មុំដែលលាយដោយក្ខនឃ្មុំ ដូចបាយមធុបាយាសដែលមានទឹកតិច ។ កាលកើតផែនដីនោះ ទីពោធិបល្ល័ង្ក មានគុម្ពឈូកមួយដើមដុះឡើងជាបុព្វនិមិត្ត ។ ក្នុងទីពោធិបល្ល័ង្កនោះ បើមានព្រះពុទ្ធ ១ អង្គនឹងឧប្បត្តិឡើងក្នុងកប្បនោះឈូកមានផ្កាតែមួយ (១), កប្បមានសភាពបែបនេះហៅថា « សារកប្ប » ។ បើមានព្រះពុទ្ធ ២ អង្គនឹងឧប្បត្តិឡើងក្នុងកប្បនោះ ឈូកមានផ្កាពីរ, កប្បមានសភាពបែបនេះហៅថា « មណ្ឌកប្ប », ។ បើមានព្រះពុទ្ធបីអង្គនឹងឧប្បត្តិឡើងក្នុងកប្បនោះ ឈូកមានផ្កាបី កប្បមានសភាពបែបនេះហៅថា « វរកប្ប » ។ បើមានព្រះពុទ្ធ ៤ អង្គនឹងឧប្បត្តិឡើងក្នុងកប្បនោះ ឈូកមានផ្កាបួន, កប្បមានសភាពបែបនេះហៅថា « សារមណ្ឌកប្ប » ។ បើមានព្រះពុទ្ធ ៥ អង្គនឹង ឧប្បត្តិឡើង

---

១ - ន័យខ្លះថាក្នុងផ្កាឈូកនោះ មានគ្រឿងបរិក្ខារទាំង ៨, កាលផ្កានោះកើតឡើង មហាព្រហ្មចុះមកកាច់យកទៅទុកនៅព្រហ្មលោកដល់ព្រះពុទ្ធចេញបព្វជ្ជាយកមកថ្វាយ

ក្នុងកប្បនោះ ឈូកមានផ្កាប្រាំ, កប្បមានសភាពបែបនេះហៅថា «ភទ្ទកប្ប» ។ បើមិនមានព្រះពុទ្ធទ្រង់ឧប្បត្តិឡើងក្នុងកប្បនោះទេ គ្មានដើមឈូកដុះជាបុព្វនិមិត្តឡើយ, កប្បមានសភាពបែបនេះហៅថា «សុញ្ញកប្ប» ។

ផ្កាឈូកនោះ ១ ក្តី ២ ក្តី ៣ ក្តី ៤ ក្តី ៥ ក្តី កើតឡើងជាប់គ្នាតែនឹងដើមមួយ ដូចជាចង្កោមផ្កាកណ្ណិកា ។

គ្រានោះឯងសត្វចុះមកអំពីព្រហ្មលោកជាច្រើន មានសត្វខ្លះជាអ្នកឡេះឡោះ ឃើញដីមានរសឆ្ងាញ់នោះ ក៏គិតថាយីអើនេះជាអ្វីអេះ! ក៏យកចង្អុលដៃ ក្តិចយកដីមានរសនោះមកលិទ្ធមើល រសដីក៏ជ្រួតជ្រាបទៅសព្វសរសៃសម្រាប់ទទួលនូវរស សេចក្តីប្រាថ្នាក្នុងរសក៏កើតឡើងដល់សត្វនោះ ។ មានសត្វដទៃទៀតយកគម្រាប់តាម នាំគ្នាយកចង្អុលដៃ ក្តិះយកដីមានរសមកលិទ្ធភ្លក់មើល រសដីក៏ជ្រួតជ្រាបទៅក្នុងសរីរៈកាយរបស់សត្វនោះៗ ។ លំដាប់នោះសត្វទាំងឡាយ ក៏នាំគ្នាកាយយកដីមានរសមកពូតធ្វើជាពំនូតហោយបរិភោគ ។ កាលបើសត្វទាំងនោះបរិភោគដីមានរសហើយ ពន្លឺដែលភ្លឺចេញអំពីកាយនៃសត្វទាំងនោះ ក៏សាបសូន្យបាត់ទៅ ងងឹតក៏កើតឡើង, សត្វទាំងនោះឃើញងងឹតក៏ភ័យខ្លាចគ្រប់ៗគ្នា ។

គ្រានោះសុរិយមណ្ឌល មានទទឹងនិងបណ្ដោយ ៥០ យោជន៍ ក៏កើតឡើងដើម្បីកំចាត់បង់នូវភ័យនៃសត្វទាំងនោះ ។ ឃើញសុរិយមណ្ឌលហើយត្រេកអររីករាយនាំគ្នាហៅថា សុរិយៈ ។ ៗ ព្រះអាទិត្យផ្ដើមពីក្នុងវេលាថ្ងៃហើយលិចបាត់ទៅ ។ សត្វទាំងនោះកើតភ័យម្ដងទៀតនិយាយគ្នាថា យើងបានពន្លឺហើយ ពន្លឺនោះបាត់ទៅវិញ យើងបានពន្លឺដទៃទៀតហ្ន៎ ! ។

៥ គ្រានោះចន្ទមណ្ឌលមានទទឹងនិងបណ្ដោយ ៤៩ យោជន៍ ក៏កើតឡើង ។ សត្វទាំងនោះបានឃើញចន្ទមណ្ឌលហើយត្រេកអររីករាយនាំគ្នា ហៅថា ចន្ទៈ ។ ដូច្នេះ ។

កាលបើព្រះអាទិត្យព្រះចន្ទកើតប្រាកដហើយ ផ្កាយនក្ខត្តឫក្សកើតឡើង, វេលាថ្ងៃនិងយប់ក៏កើតឡើង, ១ ខែនិងកន្លះខែក៏កើតឡើងរដូវនិងឆ្នាំក៏កើតឡើង, ភ្នំព្រះសុមេរុ, ភ្នំហិមវន្ត, ភ្នំចក្រវាឡ, ទ្វីបទាំង ៤ និងសមុទ្រក៏កើតឡើងប្រាកដ ក្នុងថ្ងៃពេញបូណ៌មីខែផល្គុនមិនមុនមិនក្រោយ, ដូចមានប្រាប់បញ្ជាក់ក្នុងគម្ពីរវិសុទ្ធិមគ្គត្រង់អភិញ្ញានិទ្ទេសថាៈ តេ ច ខោ អបុព្វំ អចរិមំ ផគ្គុណបុណ្ណមិទិវសេយេវ បាតុភវន្តិ ដូច្នេះ ។

កាលសត្វទាំងនោះបរិភោគដីមានរស យកដីជាចំណីអាហារហើយ

ស្ថិតនៅអស់កាលជាយូរអង្វែង, សេចក្ដីរឹងប៉ឹងក្នុងកាយរបស់សត្វទាំងនោះ ក៏កើតឡើង ពណ៌សម្បុរក៏ប្លែក ៗ គ្នាប្រាកដឡើង ។ សត្វខ្លះមានសម្បុរល្អ ខ្លះមានសម្បុរអាក្រក់ ។ ពួកសត្វដែលមានសម្បុរល្អ មើលងាយពួកសត្វដែលមានសម្បុរអាក្រក់ថា: ពួកយើងមានសម្បុរល្អជាងសត្វពួកនុ៎ះ យើងគ្រាន់បើប្រសើរជាង, សត្វពួកនុ៎ះមានសម្បុរអាក្រក់អន់ជាងពួកយើង ៗ មិនត្រូវរាប់រកគួរសមនឹងពួកសត្វនុ៎ះឡើយ ។ កាលបើសត្វទាំងនោះមានសេចក្ដីប្រកាន់ខ្លួននិងការមើលងាយគ្នាជាបច្ច័យហើយ ដីមានរសឆ្ងាញ់ពិសារនោះ ក៏សាបសូន្យអស់ទៅ ។ លុះដីមានរសនោះអស់ហើយ បប្បដកៈក្រមរផែនដីក៏កើតប្រាកដឡើង ។ ក្រមរផែនដីនោះមានសណ្ឋានដូចជាផ្សិតក្បាលពស់ មានពណ៌ដូចសប្បិស្រស់ឬដូចនវនីតស្រស់ មានរសឆ្ងាញ់ពិសាដូចទឹកឃ្មុំដែលណាយដោយកូនឃ្មុំ ។

គ្រានោះឯង សត្វទាំងនោះក៏នាំគ្នាបរិភោគក្រមរផែនដីយកក្រមរផែនដីជាចំណីអាហារ ស្ថិតនៅអស់កាលជាយូរអង្វែង ។ កាលសត្វទាំងនោះ នាំគ្នាបរិភោគក្រមរផែនដី ការរឹងប៉ឹងក្នុងកាយរបស់សត្វទាំងនោះ ក៏កើតឡើងដ៏ក្រៃលែងលើសប្រមាណ ពណ៌សម្បុរក៏ប្លែក ៗ គ្នាប្រាកដឡើង ។ ពួកសត្វទាំងនោះមានសេចក្ដីប្រកាន់ខ្លួនមើល

ឆ្ងាយគ្នាដូចមុនទៀត ។ ក្រមរែងដីក៏សាបសូន្យអស់ទៅ . វល្លិ
ឈ្មោះបទាលតា មានរសផ្អែមកើតឡើង វល្លិនោះកើតប្រាកដដូចវល្លិ
ត្រកួន មានសម្បុរល្អ មានក្លិនក្រអូប មានរសឆ្ងាញ់ មានសម្បុរដូច
សប្បិសុទ្ធឬដូចនេតសុទ្ធ មានរសដូចកូនឃ្មុំលាយដោយទឹកឃ្មុំ ។ សត្វ
ទាំងឡាយនោះក៏នាំគ្នាបរិភោគ យកវល្លិបទាលតានោះជាចំណីអាហារ
ស្ថិតនៅអស់កាលជាយូរអង្វែង ។ កាលសត្វទាំងនោះបរិភោគវល្លិ
បទាលតា ការរឹងប៉ឹងនៃសរីរៈក៏កើតប្រាកដលើសប្រមាណ ពណ៌
សម្បុរក៏ប្លែកៗគ្នា ។ ពួកសត្វទាំងនោះមានសេចក្ដីប្រកាន់ខ្លួន មើល
ងាយគ្នាដូចមុនទៀត, វល្លិបទាលតាក៏សាបសូន្យបាត់ទៅ ។ ស្រូវ
សាលីដុះឯង ជាស្រូវគ្មានកន្ទក់ គ្មានអង្កាម ស្អាត មានក្លិនក្រអូប
មានផ្លែចេញមកជាចង្កោមកើតប្រាកដឡើង ។ សត្វទាំងឡាយនាំគ្នា
យកស្រូវសាលីត្រង់ទីណាបរិភោគក្នុងវេលាព្រឹក ដល់វេលាល្ងាចស្រូវ
ដុះឡើងត្រង់ទីនោះ នាំគ្នាយកមកបរិភោគទៀតឥតលំបាកដើរទៅរកទី
ផ្សេងទៀតឡើយ ។ គ្រានោះសត្វទាំងឡាយ ក៏បរិភោគស្រូវសាលី
ដុះឯង យកស្រូវនោះជាចំណីអាហារ ស្ថិតនៅអស់កាលជាយូរអង្វែង ។
កាលសត្វទាំងនោះនាំគ្នាបរិភោគស្រូវនោះហើយ ការរឹងប៉ឹងនៃសរីរកាយ
ក៏កើតឡើងលើសប្រមាណ ទាំងពណ៌សម្បុរក៏ប្លែកៗ គ្នាប្រាកដឡើង

មុខដំបៅទាំងឡាយ ក៏បើកឡាយជាទ្វារតូចទ្វារធំ សម្រាប់បញ្ចេញនូវមូត្រលាមក ភេទប្រុស ភេទស្រី កើតប្រាកដឡើង ៗ ពួកស្ត្រី ៗ សំឡឹងមើលពួកប្រុស ៗ សំឡឹងមើលពួកស្ត្រីហួសវេលា តម្រេកក៏កើតឡើងសេចក្ដីក្ដៅក្រហាយព្រោះតម្រេកក៏ប្រជុំចុះក្នុងកាយ ៗ តាំងពីពេលនោះមកសត្វទាំងឡាយនាំគ្នាសេពមេថុនធម្ម ព្រោះមានរាគៈជាបច្ច័យ ៗ សម័យនោះពួកសត្វណាបានឃើញពួកសត្វដែលកំពុងសេពមេថុនធម្ម ក៏យកអាចម៍ដីបោលទៅខ្លះ យកផេះបោះទៅខ្លះ យកអាចម៍គោបោះទៅ ខ្លះជេរស្ដីបន្ទោសដល់សត្វដែលកំពុងសេពមេថុន-ធម្មនោះ ៗ កាលបើសត្វទាំងនោះ ដល់នូវភាពជាអ្នកសេពមេថុនធម្មស៊ប់ហើយ ក៏នាំគ្នាផ្ដើមធ្វើខ្ទមផ្ទះបិទបាំងការសេពអសទ្ធម្ម ៗ ផ្ទះខ្ទមកើតមានក្នុងលោកតាំងពីពេលនោះមក ។

ក្នុងកាលជាខាងក្រោយមក មានសត្វពួកខ្លះជាអ្នកខ្ជិលច្រអូសបានគិតយ៉ាងនេះថា ៖ យីអើ !! អាត្មាអញទៅយកស្រូវក្នុងវេលាព្រឹកបរិ-ភោគបានតែក្នុងវេលាព្រឹក ទៅយកក្នុងវេលាល្ងាចបរិភោគបានតែក្នុងវេ-លាល្ងាច ហត់ពេញជាលំបាកម៉្លេះ!! ណ្ហើយចុះអញគួរតែទៅយកស្រូវក្នុងវេលាព្រឹកហើយទុកបរិភោគក្នុងវេលាល្ងាចផងទើបស្រួល ៗ វេលានោះឯងមានសត្វមួយរូបចូលទៅរកសត្វនោះ និយាយបបួលថា ៖ នែសត្វ

ដំបំរនែអ្នកចូលមក  យើងនឹងទៅយកស្រូវសាលីមកធ្វើជាអាហារ ៗ សត្វនោះឆ្លើយថា: ណ្ហើយកុំ យើងបានយកមកបរិភោគគ្រប់គ្រាន់ហើយ ៗ សត្វដែលទៅបបួលនោះ  ឮដូច្នោះគិតឃើញថាស្រួលក៏យកតម្រាប់តាម ទៅយកស្រូវមកទុកបរិភោគបានចំនួនជា ២ ថ្ងៃក៏មាន ៣ ថ្ងៃក៏មាន ៤ ថ្ងៃ ក៏មាន  ច្រើនថ្ងៃជាងនេះក៏មាន ៗ

លុះសត្វទាំងនោះ  នាំគ្នាផ្ដើមបរិភោគស្រូវសាលីដែលខ្លួនបានយក មកទុកដូច្នោះហើយ កន្ទក់រុំព័ទ្ធអង្ករ អង្កាមរុំព័ទ្ធអង្ករ ក៏កើតឡើង សូម្បី កន្លែងដែលយកស្រូវនោះក៏លែងមានស្រូវដុះទៀត ៗ

គ្រានោះឯងសត្វទាំងឡាយបានប្រជុំគ្នាហើយនិយាយត្អូញត្អែរថា : ម្នាលគ្នាយើងទាំងឡាយ  ធម៌លាមកអាក្រក់កើតឡើងដល់យើងហើយ ធម៌លាមកអាក្រក់កើតប្រាកដដល់សត្វហើយ ៗ កាលពីដើមពួកយើង ជាអ្នកកើតដោយឈានចិត្ត  មានបីតិជាអាហារមានពន្លឺភ្លឺចេញអំពីកាយ ត្រេចចរទៅតាមអាកាសបានដូចបំណង  ឥឡូវសូម្បីតែស្រូវសាលីក៏មាន កន្ទក់មានអង្កាម  ទីដែលច្រូតហើយលែងដុះឡើងវិញ  ព្រោះហេតុនៃ ធម៌លាមកអាក្រក់កើតឡើងដល់យើងទាំងឡាយ  បើដូច្នេះគួរយើងចែក ស្រូវសាលីគ្នា  ចែកទីដីសម្រាប់ដាំស្រូវដល់គ្នានឹងគ្នា  ៗ លំដាប់ នោះឯងពួកសត្វទាំងឡាយ  ក៏នាំគ្នាចែកស្រូវសាលីបោះព្រំខណ្ឌដោយ

ខ្លួន ។ ។ វេលានោះមានសត្វមួយរូបជាតិជាអ្នកលោភករកក្រក់បាន លាក់សំចៃចំណែកស្រូវរបស់ខ្លួន លួចយកចំណែករបស់សត្វដទៃ ដែលគេមិនបានឲ្យមកបរិភោគ ។ សត្វទាំងឡាយក៏ចាប់សត្វនោះ លុះចាប់បានហើយក៏ស្តីបន្ទោសថា: ឱ! សត្វអើយឯងធ្វើអំពើអាក្រក់ណាស់ មិនគួរឯងលាក់សំចៃចំណែកខ្លួនទុក ហើយលួចយកចំណែករបស់សត្វដទៃមកបរិភោគសោះ ឯងកុំធ្វើយ៉ាងនេះទៀត ។ វេលាខាងក្រោយមកសត្វនោះលួចទៀតអស់វារៈពីរបីដង សត្វទាំងឡាយក៏ចាប់បានសត្វនោះទៀត លុះចាប់បានហើយក៏ស្តីបន្ទោសជាច្រើន សត្វខ្លះខះកប់នឹងដៃ ខ្លះវាយនឹងដំបង ។ ក្នុងពេលនោះការលួចក៏កើតប្រាកដឡើង, ការតិះដៀលក៏កើតប្រាកដឡើង, ការនិយាយកុហក, ការដាក់អាជ្ញាក៏កើតប្រាកដឡើងក្នុងលោក ។

ក្នុងគម្ពីរទីឃនិកាយ ត្រង់អគ្គញ្ញសូត្រប្រាប់ថា: កាលព្រះបរមគ្រូអរហន្តសម្មាសម្ពុទ្ធគង់ក្នុងវត្តបុព្វារាម បានសំដែងប្រាប់ដល់សាមណេរពីររូបថា:

អថខោ តេ វាសេដ្ឋ សត្តា សន្និបតិសុ សន្និបតិត្វា អនុត្ថុនិសុ លាមកា វត ភោ ធម្មា សត្តេសុ បាតុភូតា យត្រ ហិ នាម អទិន្នាទានំ បញ្ញាយិស្សតិ គរហា បញ្ញាយិស្សតិ មុសាវាទោ បញ្ញាយិស្សតិ ទណ្ឌាទានំ

បញ្ញាយិស្សតិ យន្នូន មយំ ឯកំ សត្តំ សម្មន្នេយ្យាម យោ នោ សម្មា ខីយិតព្វំ ខីយេយ្យ សម្មា គរហិតព្វំ គរហេយ្យ សម្មា បព្វាជេតព្វំ បព្វាជេយ្យ មយំ បនស្ស សាលីនំ ភាគំ អនុប្បទស្សាមាតិ អថខោ តេ វាសេដ្ឋ សត្តា... ដូច្នេះជាដើម ។

សេចក្ដីថា៖ ម្នាលវាសេដ្ឋៈនិងភារទ្វាជៈ គ្រានោះឯពួកសត្វទាំងនោះមកប្រជុំគ្នា លុះប្រជុំគ្នាហើយក៏ត្អូញត្អែរថា៖ យីអើហ្ន៎? ធម៌លាមកទាំងឡាយ កើតប្រាកដដល់សត្វទាំងឡាយហើយ ព្រោះថាការលួចទ្រព្យគេក៏កើតឡើង ការតិះដៀលក៏កើតប្រាកដឡើង ការនិយាយកុហកក៏កើតប្រាកដឡើង ការដាក់អាជ្ញាក៏កើតប្រាកដឡើង បើដូច្នេះគួរតែយើងសន្មតសត្វម្នាក់ ឲ្យជាអ្នកបន្ទោសសត្វដែលគួរបន្ទោសតាមហេតុ ឲ្យតិះដៀលសត្វដែលគួរតិះដៀលតាមហេតុ ឲ្យបណ្ដេញសត្វដែលគួរបណ្ដេញតាមហេតុ ឲ្យដល់ពួកយើង ចំណែកខាងពួកយើង ត្រូវជូនចំណែកស្រូវសាលីទាំងឡាយដល់សត្វនោះ ។ ម្នាលវាសេដ្ឋៈនិងភារទ្វាជៈ ទើបសត្វនោះ នាំគ្នាចូលទៅរកសត្វដែលជាអ្នកមានរូបល្អ គួររមិលមើល គួរជ្រះថ្លា មានសក្តិធំ គឺព្រះពោធិសត្វ ។ លុះចូលទៅដល់ហើយ បាននិយាយដូច្នេះថា បពិត្រសត្វដ៏ចំរើន ចូរអ្នកបន្ទោសសត្វដែលគួរបន្ទោសតាមហេតុ ចូរអ្នកតិះដៀលសត្វដែលគួរតិះដៀលតាមហេតុ ចូរ

អ្នកបណ្ដេញសត្វដែលគួរបណ្ដេញតាមហេតុចុះ ពួកយើងនឹងជូនចំណែកស្រូវសាលីទាំងឡាយដល់អ្នក ។

ព្រះពោធិសត្វបានទទួលពាក្យរបស់សត្វទាំងនោះថាស្រួលហើយ ។ តាំងពីពេលនោះមក ក៏បន្ទោសសត្វដែលគួរបន្ទោស តិះដៀលសត្វដែលគួរតិះដៀល ឬបណ្ដេញចេញតាមហេតុ ។ ពួកសត្វទាំងនោះក៏បានជូនចំណែកស្រូវសាលីដល់ពោធិសត្វគ្រប់ៗគ្នា ។ មហាជនគឺសន្មតព្រះពោធិសត្វនោះថា «មហាសន្មត» ដូច្នេះ ដោយមានបទវិគ្រោះថា មហាជនសម្មតោ, គឺ> មហាសម្មាតា (សត្វណា) ដែលមហាជនសន្មតហើយ (សត្វនោះ) ឈ្មោះ មហាសន្មតៈ សត្វគឺមហាជនសន្មតហើយ, ពាក្យថា មហាសន្មតៈ កើតមានតាំងពីពេលនោះមក ។ ពួកសត្វខ្លះហៅ ពោធិសត្វនោះថា ខត្តិយៈ ដូច្នេះក៏មាន ព្រោះព្រះពោធិសត្វនោះជាអធិបតីនៃស្រែទាំងឡាយ ដោយមានបទវិគ្រោះថា: ខេត្តានំ អធិបតិ, គឺ> ខត្តិយោ (សត្វណា) ជាអធិបតីនៃស្រែទាំងឡាយ (សត្វនោះ) ឈ្មោះ ខត្តិយៈ, សត្វជាអធិបតីនៃស្រែទាំងឡាយ ពាក្យថា ខត្តិយ ឬ ក្សត្រ មានតាំងពីពេលនោះមក ។ ពួកសត្វខ្លះហៅព្រះពោធិសត្វថា រាជា ព្រោះព្រះពោធិសត្វនោះ ញ៉ាំងសត្វទាំងឡាយឲ្យពេញចិត្តដោយធម៌ មានបទវិគ្រោះថា: ធម្មេន បរេសំ រញ្ជេតិ គឺ>

រាជា (សត្តុណា) ញុំាំងសត្វទាំងឡាយដទៃ ឲ្យពេញចិត្តដោយធម៌ (សត្តេៈ ឈ្មោះថា រាជា សត្វអ្នកញុំាំងសត្វទាំងឡាយដទៃឲ្យពេញចិត្តដោយធម៌, ពាក្យថា រាជា មានតាំងពីពេលនោះមក ។

រឿងនេះសង្ខេបតែប៉ុណ្ណេះ, ចាប់តាំងពីពេលនោះមក លោកបេះតែមានសេចក្តីចំរើនមិនចំរើន ខ័យចុះ ខ័យឡើង ជាច្រើនលើកច្រើនគ្រា, ខំនឹងនាំយករឿង ខ័យចុះ ខ័យឡើងនោះមកសំដែងតាមដែលមាននៅក្នុងគម្ពីរទីឃនិកាយ ត្រង់ចក្កវត្តិសូត្រដូចតទៅនេះ ។

កាលព្រះសម្ពុទ្ធបរមគ្រូ គង់នៅក្នុងព្រៃក្បែរមាតុលានគរ នាដែនមគធៈ ។ សម័យនោះព្រះអង្គទ្រង់សំដែងប្រាប់ភិក្ខុទាំងឡាយថាៈ

ភូតបុព្វំ ភិក្ខវេ រាជា ទឡ្ហនេមិ នាម អហោសិ ចក្កវត្តិ ធម្មិកោ ធម្មរាជា ចាតុរន្តោ វិជិតាវី ជនបទត្ថាវរិយប្បត្តោ សត្តរតនសមន្នាគតោ ។ តស្សិមានិ សត្ត រតនានិ . . . ដូច្នេះជាដើម ។

សេចក្តីថាៈ ម្នាលភិក្ខុទាំងឡាយ កាលពីព្រេងនាយមក មានព្រះរាជា ១ ព្រះអង្គ ព្រះនាមទឡ្ហនេមិ ជាស្តេចចក្រពត្តិ ព្រះអង្គជាធម្មិកធម្មរាជា ជាឥស្សរៈលើផែនដីដែលមានសមុទ្រទាំង ៤ ជាទីបំផុតជាស្តេចឈ្នះសង្គ្រាម ទ្រង់មានជនបទដល់នូវសេចក្តីមាំមួនស្ថាពរទ្រង់បរិបូណ៌ដោយរតន ៧ ប្រការ ។ ព្រះបាទទឡ្ហនេមិនោះទ្រង់ត្រួតត្រាគ្រប់គ្រងផែនដីដែល

មានសាគរជាព្រំប្រទល់នេះដោយធម៌ដ៏ស្មើ មិនបាច់ប្រើប្រាជ្ញា មិនបាច់ប្រើគ្រឿងសស្ត្រាវុធ ។ លុះកាលកន្លងទៅជាច្រើនរយច្រើនពាន់ឆ្នាំ ទើបព្រះបាទទឡ្ហនេមិទ្រង់ត្រាស់នឹងបុរសម្នាក់ថា បើអ្នកឃើញចក្ររតន៍ច្យុតឃ្លាតចាកទីតាំងកាលណា អ្នកត្រូវប្រាប់ដល់យើងក្នុងកាលនោះ ។ លុះកាលកន្លងទៅជាច្រើនពាន់ឆ្នាំ បុរសនោះបានឃើញចក្ររតន៍ឃ្លាតចាកទី ក៏ចូលទៅទូលដល់ព្រះបាទទឡ្ហនេមិ ។

គ្រានោះឯងព្រះបាទទឡ្ហនេមិទ្រង់ហៅព្រះរាជកុមារជាបុត្រច្បងមក ហើយទ្រង់ត្រាស់ដូច្នេះថា ម្នាលកុមារមាសឪពុក ឮថាចក្ររតន៍ទិព្វរបស់យើងច្យុតឃ្លាតចាកទីហើយ, សេចក្តីនេះឪពុកធ្លាប់ឮថាបើចក្ររតន៍ទិព្វរបស់ស្តេចចក្រពត្តិអង្គណាច្យុតចាកទីហើយ តពីនោះមក ស្តេចអង្គនោះមិនរស់នៅបានយូរឡើយ ឯកាមរបស់មនុស្សឪពុកបានបរិភោគឆ្អែតស្កប់ស្កល់ហើយ ។ សម័យនេះជាសម័យដែលឪពុកគួរស្វែងរកកាមជាទិព្វវិញ. ម្នាលកុមារមាសឪពុក ចូរអ្នកគ្រប់គ្រងផែនដី ដែលមានសមុទ្រជាព្រំប្រទល់នេះចុះ ឯឪពុកនឹងកោរសក់ពុកមាត់ពុកចង្កា ស្លៀកដណ្តប់សំពត់កាសាវៈ ចេញចាកផ្ទះចូលកាន់ផ្នួស ។ លំដាប់នោះឯងព្រះបាទទឡ្ហនេមិទ្រង់លួងលោមព្រះរាជបុត្រច្បង ឲ្យគ្រប់គ្រងរាជសម្បត្តិដោយប្រពៃហើយ ក៏ទ្រង់ចេញចាករាជាគារស្ថាន ចូលទៅ

បួសជាឥសី ។

កាលបើព្រះរាជឥសីទើបនឹងទ្រង់ព្រះផ្នួសបាន ៧ ថ្ងៃ ចក្ររតនក៏បាត់ទៅ ។ លំដាប់នោះមានបុរសម្នាក់ចូលគាល់ព្រះរាជបុត្រដែលទើបនឹងបានពុទ្ធាភិសេកជាក្សត្រថ្មីនោះបានក្រាបទូលថាបពិត្រព្រះសម្មតិទេព សូមទ្រង់ជ្រាប ព្រោះចក្ររតនទិព្វបាត់ទៅហើយ ។ ព្រះរាជាទ្រង់ព្រះសណ្ដាប់ហើយទ្រង់តូចព្រះរាជហឫទ័យ សោយនូវសេចក្ដីមិនសប្បាយ ទើបស្ដេចចូលទៅគាល់ព្រះរាជឥសីជាបិតា ក្រាបទូលថា៖ បពិត្រព្រះសម្មតិទេពសូមទ្រង់ជ្រាប ព្រោះចក្ររតនទិព្វបាត់ទៅហើយ ។ ព្រះរាជឥសីទ្រង់ត្រាស់នឹងព្រះរាជបុត្រថា ម្នាលបាកាលបើចក្ររតនបាត់ទៅហើយអ្នកកុំតូចចិត្ត កុំអន់ចិត្តឡើយ អ្នកចូរប្រព្រឹត្តចក្កវត្តិវត្ត (វត្តរបស់ស្ដេចចក្រ) ដ៏ប្រសើរចុះ, បើអ្នកបានប្រព្រឹត្តល្អហ្មត់ចត់ហើយ ចក្ររតនទិព្វមានកាំមួយពាន់ បរិបូណ៌ដោយអាការសព្វគ្រប់នឹងកើតប្រាកដដល់បាដែលកក់កេសាហើយរក្សាឧបោសថសីលស្ថិតនៅលើប្រាសាទក្នុងថ្ងៃ ១៥ ជាថ្ងៃឧបោសថនោះឯង ។ ក្សត្រជាព្រះរាជបុត្រក៏ទូលសួរចក្កវត្តិវត្តនឹងព្រះរាជឥសីជាបិតា ។ ប្រាប់ថា៖ ម្នាលបាបើដូច្នោះ អ្នកចូរអាស្រ័យនូវធម៌តែម្យ៉ាង ហើយធ្វើសក្ការៈចំពោះធម៌, គោរពធម៌, រាប់អានធម៌, បូជាធម៌, កោតក្រែងធម៌, យកធម៌ជាទង់ជ័យ យក

ធម៌ជាស្ពាន, យកធម៌ជាអធិបតី ចាត់ចែងនូវការរក្សាទប់ទល់ប្រកបដោយធម៌ ចំពោះជនខាងក្នុងនិងបុត្រភរិយា ចំពោះពួកពល ពួកក្សត្រ, ពួកជនចុះចូល, ពួកព្រាហ្មណ៍គហបតី, ពួកអ្នកនិគម ពួកអ្នកជនបទ, ពួកសមណព្រាហ្មណ៍ និងពួកម្រឹគបក្សី ។ ម្នាលបាអ្នកកុំធ្វើអកុសលធម៌ក្នុងដែនរបស់អ្នកឡើយ បើជនណាក្នុងដែនរបស់អ្នកមិនមានទ្រព្យ អ្នកគប្បីផ្តល់ទ្រព្យដល់ជននោះ ។ បើសមណ-ព្រាហ្មណ៍ណាមួយក្នុងដែនរបស់អ្នកជាអ្នកមិនប្រមាទ តាំងនៅក្នុងខន្តីនិងសោរច្ចៈ អ្នកគប្បីចូលទៅរកសមណព្រាហ្មណ៍នោះសព្វៗកាល ហើយសាកសួរអំពើដែលប្រកបដោយទោសនិងមិនប្រកបដោយទោស អំពើជាកុសលនិងអកុសល, បើអ្នកបានស្តាប់ពាក្យរបស់សមណព្រាហ្មណ៍នោះហើយ អ្នកគប្បីវៀរនូវអំពើជាអកុសល ហើយសមាទាននូវអំពើជាកុសល, ម្នាលបា នេះឯងជាវត្តដ៏ប្រសើររបស់ស្តេចចក្រ ។

ក្សត្រជាព្រះរាជបុត្រ បានស្តាប់ឪវាទរបស់រាជឥសីជាបិតាហើយ ក៏ទ្រង់ប្រព្រឹត្តចក្កវត្តិវត្តដ៏ប្រសើរនោះ បានកក់ព្រះកេសាសមាទានឧបោសថ ទ្រង់ស្ថិតក្នុងជាន់ប្រាសាទខាងលើ នាថ្ងៃ១៥ ដែលជាថ្ងៃឧបោសថ ។ ពេលនោះចក្ររតនៈទិព្វមានកាំមួយពាន់កើតឡើង ទ្រង់ទតឃើញហើយ មានព្រះតម្រិះថា: ចក្ររតនៈទិព្វកើតដល់ស្តេចអង្គណា

ស្ដេចអង្គនោះជាស្ដេចចក្រ ទេហ្ន៎! អាត្មាអញជាស្ដេចចក្រហើយតើ ។

គ្រានោះព្រះរាជាទ្រង់ក្រោកចាកអាសនៈ ធ្វើសំពត់ឧត្តរាសង្គៈ ឆៀងស្មាម្ខាង ព្រះហស្តឆ្វេងកាន់កុណ្ឌីមាស ព្រះហស្តស្តាំប្រស់ចក្ររតន៍ ហើយអធិដ្ឋាន សូមឲ្យចក្ររតន៍ដ៏ចំរើនប្រព្រឹត្តទៅ សូមឲ្យចក្ររតន៍ដ៏ចំរើនមានជ័យជំនះចុះ ។ គ្រានោះចក្ររតន៍ក៏អណ្ដែតត្រសែតទៅកាន់ទិសខាងកើត ស្ដេចចក្រពត្តិក៏អណ្ដែតទៅតាមចក្ររតន៍នោះ ព្រមដោយចតុរង្គសេនា ។ បើចក្ររតន៍ទៅប្រតិស្ឋាននៅប្រទេសណា ស្ដេចក៏ចូលទៅតាំងព្រះរាជនិវេសន៍ក្នុងប្រទេសនោះ ។ ឯស្ដេចជាសឹកសត្រូវទាំងឡាយដែលស្ថិតនៅក្នុងទិសខាងកើត ក៏ចូលទៅគាល់ព្រះបាទចក្រពត្តិ ហើយក្រាបបង្គំទូលថា បពិត្រមហារាជទឹកដីរបស់ខ្ញុំព្រះអង្គ ជាទឹកដីរបស់ព្រះអង្គហើយសូមព្រះអង្គប្រៀនប្រដៅចុះ ។ ព្រះបាទចក្រពត្តិមានព្រះបន្ទូលថា អ្នកទាំងឡាយមិនត្រូវសម្លាប់សត្វ, មិនត្រូវលួចទ្រព្យគេ, មិនត្រូវផឹកទឹកស្រវឹងឡើយ ។ ចូរបរិភោគតែរបស់ដែលគួរបរិភោគ ។ លំដាប់នោះចក្ររតន៍អណ្ដែតចូលសមុទ្រទៅកាន់ទិសដទៃទៀតដរាបដល់គ្រប់ទិសទាំង ៤ ព្រះបាទចក្រពត្តិក៏អណ្ដែតទៅតាម មានទំនងដូចមុនទាំងអស់ទ្រង់បង្ក្រាបសត្រូវលើផែនដីដែលមានសមុទ្រជាព្រំប្រទល់ឲ្យស្ថិតនៅក្នុងសីល ៥ អស់ហើយ ទ្រង់ត្រឡប់ទៅកាន់

ព្រះរាជធានីវិញ ចក្ររតន៍ក៏អណ្ដែតទៅស្ថិតនៅក្នុងរបៀងនៃសាលាវិ-និច្ឆ័យទៀបទ្វារព្រះបរមរាជវាំង ស្ថិតនៅទីធ្លាល់ហាក់ដូចជាបាក់ក្ដាប់-ក្ដីព្រះបរមរាជវាំងឲ្យក្ដីក្រោធក្រោក ។ ស្ដេចចក្រពត្តិអង្គនេះដល់ចាស់ព្រះអង្គទៅបានប្រគល់រាជសម្បត្តិដល់ព្រះរាជបុត្រច្បង តាមដំណើរប្រវេណីរបស់ព្រះរាជបិតា , ក្សត្រក្រោយ ៗ មកទៀតប្រតិបត្តិយ៉ាងនេះដរាបអស់ ៦ជំណាស្ដេច , ដល់មកស្ដេចទី ៧ មិនបានប្រតិបត្តិតាមប្រវេ-ណីនោះឡើយ ចក្ររតន៍ក៏មិនកើតឡើងដល់ស្ដេចអង្គនោះ ទើបទ្រង់រៀនប្រដៅប្រជាជនតាមយោបល់របស់ព្រះអង្គ ទឹកដីប្រជាជនក៏មិនបានសុខចំរើនដូចកាលស្ដេចមុន ៗ ឡើយ ។

គ្រានោះឯង ពួកអមាត្យ , មហាមាត្យ , ពួកហោរ , ពួកហ្មដ៏រ ពួកអ្នករក្សាទ្វារ និងពួកអ្នកចិញ្ចឹមជីវិតដោយមន្ត ក៏ប្រជុំគ្នាចូលទៅក្រាបទូលព្រះរាជាថា: បពិត្រព្រះសម្មតិទេព ពួកអ្នកជនបទមិនចំរើនស្មើនឹងព្រះរាជាជាន់ដើមដែលប្រព្រឹត្តចក្កវត្តិវត្ត ដ៏ប្រសើរនោះឡើយ , បពិត្រព្រះសម្មតិទេព ពួកខ្ញុំព្រះអង្គសុទ្ធតែចេះចាំនូវចក្កវត្តិវត្ត សូមព្រះអង្គសួរខ្ញុំព្រះអង្គចុះ ខ្ញុំព្រះអង្គនឹងព្យាករថ្វាយ ។ កាលនោះព្រះរាជាទ្រង់សួរនូវចក្កវត្តិវត្តនឹងពួកជនទាំងនោះ ៗ ក៏បានព្យាករថ្វាយ ។ ព្រះរាជាកាលបើបានសវនាការព្យាករណ៍របស់ពួកជននោះ

ហើយ ក៏ទ្រង់ចាត់ចែងនូវការរក្សាទប់ទល់គ្រប់គ្រងប្រកបដោយធម៌វិញ តែទ្រង់មិនបានព្រះរាជទានទ្រព្យដល់ពួកអ្នកខ្សត់ទ្រព្យឡើយ ។ កាលបើដូច្នោះហើយ សេចក្តីទាល់ក្រក៏មានច្រើនឡើង ។ កាលបើសេចក្តីទាល់ក្រកើតមានច្រើនហើយ មានបុរសម្នាក់កាន់យកទ្រព្យរបស់ជនដទៃ ដែលគេហៅថាលួច ។ ពួករាជបុរសចាប់បុរសនោះបាន នាំយកទៅថ្វាយស្តេច ហើយទូលតាមដំណើររឿង ។ ព្រះរាជាទ្រង់ត្រាស់សួរបុរសនោះថា អ្នកឯងលួចទ្រព្យគេមែនឬ ? ; ក្រាបទូលខ្ញុំព្រះអង្គលួចគេមែន ហេតុអ្វីបានជាលួច ? ; បានជាទូលព្រះបង្គំលួចព្រោះមិនមានរបស់អ្វីនឹងចិញ្ចឹមជីវិត ។ លំដាប់នោះព្រះរាជាទ្រង់ព្រះរាជទានទ្រព្យដល់បុរសនោះ ហើយទ្រង់ត្រាស់បង្គាប់ថា អ្នកចូរយកទ្រព្យទៅចិញ្ចឹមជីវិតខ្លួនផង ចិញ្ចឹមមាតាបិតាបុត្រភរិយាផង ។ ចូរធ្វើទក្ខិណាទានចំពោះសមណព្រាហ្មណ៍ទាំងឡាយផង ។ បុរសនោះក៏ទទួលប្រតិបត្តិតាមព្រះរាជឱង្ការ ។ កាលជាខាងក្រោយមក ពួកមនុស្សទាំងឡាយបានឮព្រះរាជាទ្រង់ព្រះរាជទានទ្រព្យដល់មនុស្ស ដែលលួចទ្រព្យដូច្នោះ ក៏នាំគ្នាលួចទ្រព្យរបស់ជនដទៃកាន់តែច្រើនឡើងៗ ។ ( អកុសលកម្មបថក៏ចាប់កំណើតកើតឡើងទៀតក្នុងលោក តាំងពីកាលនោះមក ) ។ លំដាប់នោះមានបុរសម្នាក់លួចទ្រព្យគេ ពួករាជបុរសចាប់បាននាំយកទៅ

ថ្វាយស្តេច ។ ព្រះរាជាទ្រង់ត្រាស់សួរបុរសនោះ ៗ ក៏ក្រាបទូលតាម ដំណើរដូចបុរសអ្នកលួចមុន ៗ វេលានោះព្រះរាជាទ្រង់ត្រិះរិះថា: បើរកគ្នាអញនៅតែឲ្យទ្រព្យដល់អ្នកលួចទៀត អំណើសតទៅ អទិន្នា ទាននឹងរឹងរិតតែចំរើនឡើងក្នុងលោក បើដូច្នោះគួរតែការគ្នាអញផ្ចាញ់ ផ្ចាលកាត់ក្បាលអ្នកលួចចេញ ៗ ព្រះរាជាក៏ត្រាស់បង្គាប់រាជបុរស ថា: នែ! ប្រស្តង អ្នកទាំងឡាយចូរចងស្លាបសេកបុរសនេះឲ្យជាប់ ហើយកោរក្បាលឲ្យរលីងទូងស្គរនាំបណ្តើរសព្វច្រកល្ហក រួចនាំចេញ ទៅតាមទ្វារខាងត្បូង ហើយកាត់ក្បាលវាចេញ ៗ រាជបុរសបាន ធ្វើតាមព្រះរាជអាជ្ញា មនុស្សទាំងឡាយបានឮដំណឹងថាព្រះរាជាទ្រង់ បង្គាប់ឲ្យកាត់ក្បាលជនអ្នកលួចទ្រព្យដូច្នោះ ក៏នាំគ្នាធ្វើគ្រឿងសស្ត្រាវុធ ដ៏មុតក្លា ហើយនាំគ្នាប្លន់កាប់សម្លាប់អ្នកស្រុកខ្លះ អ្នកនិគមខ្លះ អ្នក នគរខ្លះ អ្នកដើរផ្លូវខ្លះ អូសយកទ្រព្យរបស់ជនទាំងនោះហើយកាប់ សម្លាប់ទៀត, បាណាតិបាតក៏កើតឡើងក្នុងលោកនាវេលានោះ ៗ

កាលបើព្រះរាជាមិនព្រះរាជទានទ្រព្យដល់ជនអ្នកគ្មានទ្រព្យហើយ អទិន្នាទានក៏មានច្រើនឡើង, បាណាតិបាតក៏កើតច្រើនឡើង ៗ តមក មានបុរសម្នាក់លួចទ្រព្យជនដទៃ រាជបុរសចាប់បានយកមកថ្វាយព្រះ រាជា ៗ ត្រាស់សួរបុរសនោះ ៗ មិនហ៊ានឆ្លើយតាមពិតខ្លាចក្រែងព្រះរាជា

សម្លាប់ក៏ឆ្លើយកុហកថាមិនបានលួចទេ, មុសាវាទក៏កើតមានឡើង ។ កាលបើមុសាវាទកើតឡើងហើយ គឺ ៤ ប្រការគឺអាយុ វណ្ណៈ សុខៈ ពលៈ របស់សត្វក៏ថយចុះមក, មនុស្សដែលមានអាយុ ១ សែនឆ្នាំថយទៅត្រឹមតែ ៨ ម៉ឺនឆ្នាំ ។ លុះកន្លងកាលយូរទៅក៏ថយចុះទៅត្រឹមតែ ៤ ម៉ឺនឆ្នាំ, ពួកអ្នកមានអាយុ ៤ ម៉ឺនឆ្នាំនោះ ថយចុះទៅត្រឹមតែ ២ ម៉ឺនឆ្នាំ ។ ពួកមនុស្សដែលមានអាយុ ២ ម៉ឺនឆ្នាំនោះ មានបុរសម្នាក់លួចទ្រព្យគេ មានបុរសម្នាក់ទៀតស្អប់បុរសនោះ ទៅទូលញុះញង់ព្រះរាជាឲ្យចាប់បុរសដែលលួចនោះ. បិសុណាវាចាក៏កើតមានឡើង ។ កូនរបស់ពួកមនុស្សដែលមានអាយុ ២ ម៉ឺនឆ្នាំនោះ ក៏ថយចុះទៅត្រឹមតែអាយុ ១ ម៉ឺនឆ្នាំ ។ ពួកមនុស្សអ្នកមានអាយុ ១ ម៉ឺនឆ្នាំនោះខ្លះមានពណ៌សម្បុរល្អ ខ្លះអាក្រក់ ពួកអ្នកមានពណ៌សម្បុរអាក្រក់ស្រឡាញ់ពួកអ្នកមានពណ៌សម្បុរល្អ ក៏ប្រព្រឹត្តល្មើសចំពោះភរិយាបុត្រភរិយារបស់ជនដទៃ កាមេសុមិច្ឆាចារក៏កើតមានឡើង ។ កូនរបស់ជនអ្នកមានអាយុ ១ ម៉ឺនឆ្នាំនោះក៏ថយចុះទៅត្រឹមតែអាយុ ៥ ពាន់ឆ្នាំវិញ ។ ក្នុងពេលដែលពួកមនុស្សមានអាយុ ៥ ពាន់ឆ្នាំនោះ ធម៌ ២ ប្រការគឺៈ ផរុសវាចា និងសម្ផប្បលាបៈកើតមានឡើង ។ កូនរបស់ជនអ្នកមានអាយុ ៥ ពាន់ឆ្នាំនោះក៏ថយចុះទៅត្រឹមតែអាយុ ២ ពាន់ ៥ រយឆ្នាំ ធម៌ ២ ទៀតគឺអភិជ្ឈា

ធម៌ព្យាបាទៈ កំកើតមានឡើងក្នុងពួកមនុស្សជំនាន់នោះ ។ កូនរបស់ពួកអ្នកមានអាយុ ២ ពាន់៥រយឆ្នាំនោះ ក៏ថយចុះនៅត្រឹមតែអាយុ ១ ពាន់ឆ្នាំវិញ ធម៌មួយទៀតគឺមិច្ឆាទិដ្ឋិក៏កើតមានឡើងក្នុងពួកមនុស្សជំនាន់នោះ ។

## បញ្ជាក់សេចក្ដី

អកុសលកម្មបថទាំង ១០ ដែលកើតឡើងក្នុងលោក មិនមែនកើតឡើងគ្នាដូចទាំងផ្លូវកុសលកម្មបថទេ កើតយ៉ាងនេះគឺ:

១– អទិន្នាទាន　　៦– ផរុសវាចា
២– បាណាតិបាត　　៧– សម្ផប្បលាបៈ
៣– មុសាវាទ　　៨– អភិជ្ឈា
៤– បិសុណាវាចា　　៩– ព្យាបាទ
៥– កាមេសុមិច្ឆាចារ　　១០– មិច្ឆាទិដ្ឋិ

## ខាងកុសលកើតយ៉ាងនេះ

១– វៀរចាក បាណាតិបាត　　៥· វៀរចាក បិសុណាវាចា
២– „ អទិន្នាទាន　　៦– „ ផរុសវាចា
៣– „ កាមេសុមិច្ឆាចារ　　៧– „ សម្ផប្បលាបៈ
៤– „ មុសាវាទ　　៨– „ អភិជ្ឈា

៩- " ព្យាបាទ ១០ " មិច្ឆាទិដ្ឋិ

កាលបើអកុសលកម្មបថទាំង ១០ កើតច្រើនក្នុងលោកហើយ, កូនរបស់ជនអ្នកមានអាយុ ១ ពាន់ឆ្នាំនោះ ក៏ថយចុះនៅតែអាយុ ៥ រយឆ្នាំ ។ ក្នុងពេលនោះធម៌អាក្រក់ ៣ យ៉ាងកើតឡើងទៀតគឺ:

១ អធម្មរាគៈ ត្រេកត្រអាលខុសគន្លងធម៌ គឺមនុស្សមានតម្រេកក្នុងមាតាបិតា, ម្ដាយធំ, ឪពុកធំ ម្ដាយមីង ឪពុកមា, បងប្អូនបង្កើត និងបុត្រធីតារបស់ខ្លួន ។

២- វិសមលោភៈ ចង់បានហួសប្រមាណ ចង់បានឥតបែបគឺ: របស់ដែលមិនគួរខ្លួនបានក៏ចង់បានដែរ នៅស្រុកឯណេះចង់បានរបស់ស្រុកឯណោះ នៅនគរឯណេះចង់បាននគរឯណោះ . . . ។

៣- មិច្ឆាធម្មៈ ប្រព្រឹត្តខុសគន្លងធម៌ បានដល់តម្រេករបស់បុរសក្នុងបុរស តម្រេករបស់ស្ត្រីក្នុងស្ត្រី ។

កាលបើធម៌ទាំង ៣ នេះចំរើនឡើងហើយ កូនរបស់ជនអ្នកមានអាយុ ៥ រយឆ្នាំ ក៏ថយចុះនៅតែអាយុ ២៥០ ឆ្នាំ ។ ពេលនោះមនុស្សមិនសូវគោរពមាតាបិតាគ្រូអាចារ្យចាស់ព្រឹទ្ធាចារ្យឡើយ អាយុក៏ចេះតែថយចុះមកនៅត្រឹម ១០០ ឆ្នាំ; ក្នុងរយៈកាលអាយុ ១០០ ឆ្នាំនេះ ព្រះសម្មាសម្ពុទ្ធបរមគ្រូរបស់យើងទ្រង់ស្ដេចចុះចាកស្ថានតុសិត មកចាប់បដិសន្ធិ

ក្នុងផ្ទៃនៃព្រះនាងសិរីមហាមាយា ជាភរិយាអគ្គទេពីរបស់ព្រះបាទសិរី-សុទ្ធោទនៈ នាក្រុងកបិលពស្តុ, ទ្រង់ចេញបព្វជ្ជាបានត្រាស់ជាព្រះពុទ្ធ, ព្រះអង្គទ្រង់បរិនិព្វានក្នុងព្រះជន្មគំរប ៨០ ឆ្នាំ, បានប្រតិស្ឋានព្រះពុទ្ធសាសនាទុក ៥ ពាន់ឆ្នាំតមកទៀត ។ ឥឡូវនេះព្រះពុទ្ធសាសនាកន្លងទៅអស់ ២៥០០ ឆ្នាំហើយ អាយុរបស់មនុស្សសព្វថ្ងៃនេះថយនៅតែ ៧៥ ឆ្នាំទេ: ព្រោះមានក្បួនឲ្យគិតថា បើឆ្នាំកន្លងទៅ ១០០ អាយុក្ស័យរបស់មនុស្សថយអស់ ១ ឆ្នាំ ។

ការថយចុះអាយុរបស់មនុស្សសព្វថ្ងៃនេះមិនទាន់ដល់កំណត់ទេ នៅមានថយចុះទៅទៀតដរាបដល់មនុស្សមានអាយុត្រឹមតែ ១០ ឆ្នាំ, ដូចមានព្រះពុទ្ធដីកាសំដែង មាននៅក្នុងគម្ពីរទីឃនិកាយថា:

ភវិស្សតិ ភិក្ខវេ សោ សមយោ យំ ឥមេសំ មនុស្សានំ ទសវស្សាយុកា បុត្តា ភវិស្សន្តិ ដូច្នេះជាដើម ។

សេចក្តីថា: ម្នាលភិក្ខុទាំងឡាយ តទៅខាងមុខ នឹងមានសម័យដែលកូនរបស់មនុស្សទាំងនេះមានអាយុ ១០ ឆ្នាំ កាលបើមនុស្សមានអាយុ ១០ ឆ្នាំ ពួកនាងកុមារិកាមានអាយុ ៥ ឆ្នាំ នឹងល្មមឲ្យមានប្តី ម្នាលភិក្ខុទាំងឡាយកាលបើមនុស្សមានអាយុ ១០ ឆ្នាំ រសជាតិប្រសើរគឺទឹកឃ្មុំ ទឹកដោះខាប់ ប្រេង ទឹកអំពៅ អំបិល នឹងបាត់អស់ទៅ មនុស្សទាំង

ក្លាយស៊ីតែស្មៅតែលលក យកស្មៅតែលលកជាអាហារ, កុសលកម្មបថទាំង ១០ សាបសូន្យអស់ទៅ អកុសលកម្មបថចំរើនឡើង ៗ ជនអ្នកគោរពមាតាបិតាជាដើមបាត់អស់ទៅ មនុស្សក្នុងលោកក៏ហាក់មិនស្គាល់ខុសត្រូវដូចសត្វតិរច្ឆាន ទើបកើតអន្តរាយមួយយ៉ាងធំក្នុងវេលាកាលនោះឯង ហៅថាកើតសត្ថន្តរកប្ប មនុស្សទាំងអស់ក្នុងលោកត្រូវវិនាសដោយគ្រឿងសស្ត្រាវុធ ។ ក្នុងពេលដែលកើតសត្ថន្តរកប្បនោះ មនុស្សមានគ្រឿងសស្ត្រាវុធគ្រប់ដៃ ឃើញមនុស្សដូចគ្នា ដូចព្រានព្រៃឃើញម្រឹគ គឺមាតាបិតាឃើញកូន ។ ឃើញមាតាបិតា កើតសេចក្តីក្រោធខឹងសុះដេញកាប់គ្នា ក្នុងរវាង៧ថ្ងៃសូន្យមនុស្សក្នុងលោក. លើផែនដីប្រឡាក់សុទ្ធតែឈាម ។ លុះ ៧ ថ្ងៃកន្លងទៅ មានមនុស្សដែលគេរួចទៅពួនក្នុងព្រៃស្បាតជាដើម នាំគ្នាចេញមកវិញដើរស្កាត់រកគ្នា ក្នុងស្រុកនិគមជនបទមួយ ៗ មានពីរបីនាក់ លុះបានជួបគ្នាហើយក៏ឱបគ្នាទៅវិញទៅមកនិយាយរកទាក់រកគ្នា មានចិត្តស្រឡាញ់គ្នាដូចបងប្អូនបង្កើត ។

ការកើតសត្ថន្តរកប្បនេះ បើគិតពីត្រឹម ព. ស. ២៥០០ នេះ ទៅនៅតែជាង ៦.៥០០ ឆ្នាំទៀតទេដល់ហើយ ( សូមគិតដេញមើលតាមដែលកន្លងទៅ ១០០ ឆ្នាំហើយថយអស់អាយុ ១ ឆ្នាំ ) ។

ឯមនុស្សដែលសល់នៅទាំងប៉ុន្មាន កាលបើបានជួបគ្នាហើយក៏

ជំនុំគាថា: ពួកមនុស្សដែលវិនាសសូន្យក្នុងលោកយ៉ាងនេះមកតែអំពីការប្រព្រឹត្តអកុសលធម៌ បើដូច្នេះមានតែពួកយើងនាំគ្នាប្រព្រឹត្តកុសលធម៌វិញ តើគួរប្រព្រឹត្តដូចម្ដេច? ហើយចុះពួកយើងគួរវៀរចាកបាណាតិបាត ព្រោះសត្វទាំងអស់ក្នុងលោកសុទ្ធតែចង់រស់គ្រប់គ្នា បើយើងសម្លាប់គេ យើងត្រូវតែគេសម្លាប់វិញមិនខាន ។ លុះគិតដូច្នេះហើយក៏នាំគ្នាតមមិនសម្លាប់សត្វទាំងពួង, កុសលកម្មបថទី ១ ក៏កើតឡើងក្នុងលោកនាវេលានោះឡើងវិញ (១) ។ កូនរបស់មនុស្សអ្នកមានអាយុ ១០ ឆ្នាំនោះក៏មានអាយុឡើងដល់ ២០ ឆ្នាំទើបស្លាប់ ។ លុះកន្លងកាលយូរទៅពួកមនុស្សទាំងនោះមានសេចក្ដីត្រិះរិះថា ពួកយើងដែលចំរើនអាយុឡើងវិញព្រោះតែរក្សានូវកុសលធម៌ បើដូច្នេះយើងនាំគ្នារក្សានូវកុសលធម៌នោះឲ្យច្រើនក្រៃលែងឡើងទៀត ។ ពួកមនុស្សទាំងនោះបាននាំគ្នារក្សាកុសលកម្មបថម្ដងមួយ ៗ ដរាបដល់គ្រប់ទាំង ១០ អាយុក៏ចេះតែចំរើនឡើងជាទ្វេភាគដរាបដល់មនុស្សមានអាយុ ៨ ម៉ឺនឆ្នាំ (២) ពួកមនុស្សដែលមានអាយុ ៨ ម៉ឺនឆ្នាំនោះ នាងកុមារិកាមានអាយុ ៥ រយឆ្នាំល្មមឲ្យមាន

---

១- ន័យខ្លះថា នៅវេលាដែលសត្វទាំងនោះ បានរក្សាកុសលកម្មបថទី១ ហើយមានភ្លៀងធ្លាក់ចុះជាខ្លាំងនាំសាកសពចំណាក់ទៅក្នុងទន្លេសមុទ្រ ហើយមានផ្កាទិព្វធ្លាក់ចុះជាច្រើន

២- ន័យខ្លះថាឡើងដល់១អសង្ខេយ្យ ទើបថយមកវិញ ។

ស្វាមី ។ អាពាធរបស់មនុស្សក្នុងជំនាន់នោះមានតែ៣គឺ ចំណង់ក្នុង
អាហារ ១ បរិភោគអាហារមិនបាន ១, សេចក្ដីគ្រាំគ្រានៃរាងកាយ ១ ។
កាលមនុស្សមានអាយុ ៨ ម៉ឺនឆ្នាំនោះជម្ពូទ្វីបនេះ ជាទ្វីបស្តុកស្តម្ភដំខូលាយ
មានស្រុកនិគមរាជធានីតៗ គ្នាមួយរយៈមាន់ហើរធ្លាក់ ពេញទៅដោយ
មនុស្សកេបខ្ទោះគ្នា ដូចជាអវិចីនរក ពុំនោះសោតដូចជាព្រៃបបុស
ឬព្រៃកំភ្លឹក ។ ក្រុងពារាណសី សព្វថ្ងៃនេះ ប្រែឈ្មោះជាកេតុមតី
រាជធានីទៅវិញ ។ ក្នុងជម្ពូទ្វីបនេះមាននគរចំនួន ៨ ម៉ឺន ៤ ពាន់ មាន
នគរកេតុមតីជាប្រធាន មានមហាក្សត្រមួយព្រះអង្គព្រះនាម សង្ខៈ កើត
ក្នុងនគរកេតុមតីនោះឯង ជាស្ដេចចក្រពត្តិ ជាឥស្សរៈលើផែនដីដែល
មានសមុទ្ទទាំង ៤ ជាព្រំប្រទល់ ទ្រង់មានជនបទស្ថិតស្ថេរបរិបូណ៌ដោយ
កែវ ៧ ប្រការ ។ លុះកាលកន្លងយូរទៅ ព្រះមានព្រះភាគទ្រង់ព្រះនាម
មេតេយ្យៈទ្រង់ឧប្បត្តិកើតក្នុងលោក, ឧប្បត្តិកើតក្នុងត្រកូលព្រាហ្មណ៍
ដែលជាធំក្នុងនគរកេតុមតីនោះឯង, មាតារបស់ព្រះអង្គព្រះនាមព្រហ្មវតី
បិតាព្រះនាមសុព្រហ្ម ។ សម័យនោះ មនុស្សលោកបរិបូណ៌ដោយសុខ
ភាពគ្រប់យ៉ាងហាក់បីដូចជានៅក្នុងឋានសួគ៌ ៕ ព្រះសម្ពុទ្ធព្រះនាម
មេតេយ្យៈនោះ មានព្រះជន្មាយុចំនួន ៨ ម៉ឺនឆ្នាំទើបបរិនិព្វាន ៕

កាលដែលព្រះសម្ពុទ្ធព្រះនាម មេតេយ្យៈ បរិនិព្វានហើយកន្លង

កាលយូរបន្តិចទៅទៀត ភទ្ទកប្បផែនដីយើងនេះដល់កំណត់អាយុហើយ ត្រូវភ្លើងនេះរំលាយឲ្យវិនាសក្ស័យ សម័យនោះឯង ។ ព្រោះហេតុនោះ សូមពុទ្ធមាមកជនទាំងឡាយ ខំបំពេញកុសលធម៌គ្រប់ ៗ គ្នាកុំខាន ។

( ចប់កប្បកថាដោយសង្ខេប )

ព្រះបាឡាត់ឧត្តមលិខិត សុន · ស៊ី

សិទ្ធត្ថោ

គ្រូបង្រៀនបាលីនៅវត្តលង្កា

ក្រុងភ្នំពេញ

ការវែកញែកគំនិត ពិចារណាគម្ពីររឿងកប្ប ដែលនិយាយអំពី ទឹកដីមេឃ អាកាស ភ្នំ ព្រៃព្រឹក្សា ស្ថាននរក ស្ថានសួគ៌ ស្ថានព្រហ្ម ជាដើម ជាភូមិសាស្ត្រយ៉ាងកម្រុកចំលោក ដែលមានតែព្រះសម្ពុទ្ធ និងព្រះអរហន្តទ្រង់ញាណ ទើបអាចដឹងបាននោះច្រើនតែគាត់ប្រឡំ ព្រោះហួសវិស័យខួរក្បាលមនុស្សលោក ។ មិនអាចគិតបានប្រមាណត្រូវ ទៅមិនដល់ មើលមិនឃើញ ។

ការមិនអាចគិតបាន ប្រមាណត្រូវ ទៅមិនដល់ មើលមិនឃើញ នេះហើយជាបច្ច័យរបស់អ្នកវិទ្យាសាស្ត្របច្ចុប្បន្នដែលនាំឲ្យអ្នកទាំងនោះគ្មានជំនឿ បដិសេធថាគ្មានអ្វីក្រៅពីទ្វីប ពីភ្នំ ពីសមុទ្ទ ពីប្រទេស ដែលគេបានទៅដល់មើលឃើញនោះឡើយ ។

* សូមលើកឧទាហរណ៍មួយមកពិចារណាវែកញែក ដូចតទៅនេះ ៖

## អំពីទ្វីប

មនុស្សលោកបច្ចុប្បន្នដែលជឿជំនឿនឹងអ្នកប្រាជ្ញវិទ្យាសាស្ត្រ គេមិនជឿថាមានទ្វីប ៤ ដូចក្នុងច្បាប់ពុទ្ធសាសនាទេ ព្រោះក្នុងផែនដីលោក គ្មានឧត្តរកុរុទ្វីប, អបរគោយានទ្វីប, បុព្វវិទេហទ្វីប និងជម្ពូទ្វីបឡើយ មានតែទ្វីបអាស៊ី អឺរ៉ុបជាដើម ។

ឯជម្ពូទ្វីបនេះទៀត គឺមិនប្រាកដជានៅត្រង់ទីណា ទុះជាត្រង់ប្រទេសឥណ្ឌាសព្វថ្ងៃ, បើសំគាល់ថាត្រង់តែប្រទេសឥណ្ឌាប៉ុណ្ណោះ ឃើញថាមិនស្របគន្ថគម្ពីរដែលប្រាប់បញ្ជាក់ថា " មនុស្សក្នុងជម្ពូទ្វីបនោះខុសពីទ្វីបទាំងបី គឺស្ត្រីមានគភ៌ ៩ ឬ ១០ ខែទើបសម្រាលកូន , មនុស្សក្នុងជម្ពូទ្វីបនោះចិញ្ចឹមជីវិតដោយកសិកម្មនិងពាណិជ្ជកម្មជាដើម មិនមែនរស់នៅដោយស្រួលដូចទ្វីបទាំងបីទៀត ដែលមានដើមកប្បព្រឹក្ស មានជុំកែវមណី មានប្រាសាទកែវសំរាប់បង្កើតគ្រឿងឧបភោគ បរិភោគឲ្យតាមសេចក្តីប្រាថ្នារបស់មនុស្សនោះឡើយ ទាំងស្ត្រីក៏មិនមែនមានគភ៌ ៧ ថ្ងៃសម្រាលកូនទេ គឺពិតជាមានគភ៌ ៩ ឬ ១០ ខែទើបសម្រាលកូន " ។

ដូច្នេះពាក្យថាជម្ពូទ្វីបនេះគឺជាឈ្មោះរបស់ពិភពលោកដែលមានក្នុងផែនទីលោកទាំងអស់សព្វថ្ងៃនេះ គឺទ្វីបអាស៊ីក្តី-អឺរ៉ុបក្តី-អាហ្វ្រិកក្តី-អាមេរិកក្តី-អូស្ត្រានិកក្តី រួមនៅក្នុងមហាទ្វីបតែមួយហៅថាជម្ពូទ្វីបនេះឯង ព្រោះស្ត្រីជាតិអាស៊ីក្តី អឺរ៉ុបក្តី-អាហ្វ្រិកក្តី អាមេរិកក្តី អូស្ត្រានិកក្តីសុទ្ធតែមានគភ៌ ៩ ឬ ១០ ខែ ទើបសម្រាលកូន ។ ឯការរស់នៅរបស់ជនជាតិទាំងនោះក៏រស់ដោយរបរកសិកម្ម ពាណិជ្ជកម្មជាដើមដូចគ្នា ។

ឯភូមិភាគសំខាន់ជាប្រភពជាចុងសល់នៃជម្ពូទ្វីបនោះ គឺនៅប្រទេសឥណ្ឌាសព្វថ្ងៃត្រង់ភូមិភាគដែលព្រះសម្ពុទ្ធទ្រង់ប្បត្តិក្នុងលោក ។

បើយល់ថាពិភពលោកទាំងអស់ដែលមានក្នុងផែនដីលោកសព្វថ្ងៃនេះជាជម្ពូទ្វីបហើយ តើទ្វីបបីទៀតគឺឧត្តរកុរុទ្វីប, បុព្វវិទេហទ្វីប, និងអមរគោយានទ្វីបនោះ នៅឯណា? មនុស្សលោកសម័យកាំជ្រួចហោះនេះគាប់ទៅដល់ឬទេ?

ទៅមិនដល់ទេ ដែលទាំងមិនដឹងថាមានទ្វីបបីទៀតផង ។ សូម្បីអ្នកប្រាជ្ញវិទ្យាសាស្ត្រនោះបានរៀនទ្រឹស្តីពុទ្ធសាសនាដឹងថាមានក៏មិនជឿ ព្រោះអ្នកវិទ្យាសាស្ត្រគ្មានតថាគតពោធិសត្វ ។

ឯទ្វីបនោះនៅជុំវិញភ្នំសិនេរុ គឺឧត្តរកុរុទ្វីបនៅទិសខាងជើងភ្នំ, បុព្វវិទេហទ្វីបនៅទិសខាងកើតភ្នំ, អមរគោយានទ្វីបនៅទិសខាងលិចភ្នំ និងជម្ពូទ្វីបយើងនេះនៅខាងត្បូងភ្នំ ប៉ុន្តែនៅឆ្ងាយៗពីភ្នំណាស់ ។

ចុះភ្នំសិនេរុនោះនៅឯណា? នៅប្រទេសណាដែលមានក្នុងផែនដីលោកសព្វថ្ងៃថាភ្នំហិម៉ាឡាយ៉ា ហិមាល័យ ឬហិមពាន្តនោះឬ?

មិនមែនទេ! ភ្នំនេះនៅក្នុងជម្ពូទ្វីបយើងទេតើ!

ឯភ្នំសិនេរុ ដែលធ្លាប់ហៅថា ភ្នំព្រះសុមេរុនោះមិនមែននៅក្នុងទ្វីបណាមួយទេ គឺនៅក្នុងចំណោមទ្វីបទាំង ៤ ស្ថិតនៅចំភូមិភាគកណ្ដាលនៃលោកធាតុ ។

ភ្នំនោះធំខ្ពស់ណាស់ ខ្ពស់ជាងព្រះអាទិត្យព្រះចន្ទទៅទៀត

ឯព្រះអាទិត្យព្រះចន្ទនៅឯកាយត្រឹមស្មើនឹងកំពូលភ្នំយុគន្ធរ រាស់មួយ
កំពស់ភ្នំយុគន្ធរពៅទៀតទើបដល់កំពូលភ្នំសិនេរុ ។ លើកំពូលភ្នំសិនេរុ
នេះហើយជាស្ថានសួគ៌ឈ្មោះត្រៃត្រឹង្ស ជាទៅបុរីរបស់ទេវតា មានព្រះឥន្ទ
ជាស្តេចសោយរាជ្យ ។

ឯភ្នំយុគន្ធរដែលខ្ពស់ស្មើនឹងព្រះអាទិត្យព្រះចន្ទនោះ ជាភ្នំសត្ត-
ភ័ណ្ឌទី ៧ ដែលព័ទ្ធជុំវិញភ្នំសិនេរុ ។ ភ្នំទាំង ៧ នេះនៅក្នុងអាណាខេត្ត
របស់ស្ថានចាតុមហារាជិកា ជាទីលំនៅរបស់ពួកទេវតា មានស្តេចចតុ-
លោកបាលជាស្តេចសោយរាជ្យ ។

បើព្រះអាទិត្យព្រះចន្ទនៅខ្ពស់ស្មើនឹងភ្នំយុគន្ធរ ជាស្ថានរបស់ទេវតា
ដូច្នេះ ពួកអ្នកអវកាសដែលជិះកាំជ្រួចហោះ ទៅព្រះអាទិត្យព្រះចន្ទថា
ទៅដល់ហើយនោះ មុខជាបានទៅដល់ស្ថានសួគ៌ស្គាល់ពួកទេវតាមិនខាន
តើពិតជាបានទៅដល់ឬទេ? កន្លែងនោះពិតជាព្រះចន្ទឬទេ? ។

ទៅមិនដល់ជាដាច់ខាត គ្មានមធ្យោបាយនឹងទៅ ព្រោះនៅក្រៅទ្វីប
អាកាសគ្មានសរសៃទេ កាំជ្រួចហោះអាស្រ័យនឹងអាកាសមានសរសៃទើប
ហោះលឿនទៅកើត បើគ្មានសរសៃមិនអាចទ្រទ្រង់កាំជ្រួចឲ្យមានល្បឿន
ឲ្យស្ថិតនៅផ្ទៃអាកាសបាន ។ បើសិនជាហោះទៅបានខ្ពស់ជាងព្រះ
អាទិត្យព្រះចន្ទ ១០ ដងទៅទៀត ក៏ហោះបានតែក្នុងទ្វីបដែលអាកាសមាន

សារសៃប្រសាទប៉ុណ្ណោះ និងហោះធ្វើកាត់ព្រៃផងទ្វីបទៅឲ្យដល់ក្នុងសត្តបរិ-កណ្ឌ ឬទៅដល់ទ្វីបនានាទៀតនោះមិនបានទេ ។ បើអ្នកប្រាជ្ញវិទ្យាសាស្ត្ររកយានអាកាសថ្មីទៀត កុំឲ្យពាក់ព័ន្ធនឹងអាកាសយានសារសៃនោះទើបទៅដល់ ។

បើមិនដូច្នោះទេ សូមឲ្យអ្នកអាកាសចាំងនោះហោះបានថា ទៅដល់ហើយបានថតរូបយាននិងនេះយាននោះមកបង្ហាញ គឺមិនពិត គឺទៅថតតែរូបផ្គុំសង្ខាសក្នុងទ្វីប មកបញ្ឆោតអ្នកដែលគ្មានបញ្ញាបាយ និងទៅដូចខ្លួនដើម្បីឲ្យអ្នកពិភពលោកគេសរសើរតែប៉ុណ្ណោះ ព្រោះអ្នកដែលធ្វើដំណើរទៅកាន់ទីផ្សេងៗ និងអ្នកមិនបានទៅហ៊ានយកហេតុគ្នាណាស់ ។

ឯការពិចារណាវែកញែកអំពីឧបទ្រវិនាស និងកម្រចំរើន ហើយនិងការទ័យចុះឡើងនៃអាយុរបស់មនុស្សនោះ មានហេតុផលគ្រប់គ្រាប់ល្មមឲ្យអ្នកបេះដូងទ្រើស្តីពុទ្ធសាសនារកការពិតបាន វៀរតែអ្នកវិទ្យាសាស្ត្រនិងអ្នកធ្វើដំណើរនិងអ្នកវិទ្យាសាស្ត្រនោះបញ្ចេញដែលមិនជឿ ព្រោះគេធ្លាប់យល់ថាបើអ្វីៗដែលគេមិនបានឃើញ មិនបានទៅដល់គេមិនជឿ ។

ប៉ុន្តែមានអ្វីៗជាច្រើនដែរ ដូចជាជម្រៅទឹកសមុទ្រនិងទំហំទ្វីបសព្វថ្ងៃនេះជាដើម ដែលគេមិនបានទៅមើលកោសល្យស្ពាល់ក្តែក ឬទៅកាស់ខ្លួនឯងសោះនោះ គឺគេជឿកើតដែរ

(ចប់ការពិចារណាវែកញែកដោយសង្ខេប)

សុន - ស៊ុរ

មានលក់ដុំនិងរាយនូវសៀវភៅគ្រប់
ប្រភេទ ជាពិសេស សៀវភៅធម៌
តូបលេខ ៦៥
ផ្សារអូឫស្សី ក្រុងភ្នំពេញ